ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម

german
cooperation
DEUTSCHE ZUSAMMENARBEIT



# គោលការណ៍ណែនាំស្តីអំពី

## ការនាំចេញផ្លែស្វាយស្រស់
## ពីប្រទេសកម្ពុជាទៅប្រទេសចិន

giz Deutsche Gesellschaft
für Internationale
Zusammenarbeit (GIZ) GmbH

## ព័ត៌មានបោះពុម្ព


### សហការបោះពុម្ពផ្សាយដោយ

**អគ្គនាយកដ្ឋានកសិកម្មនៃ**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អគារ៥៤B/៤៩F, ផ្លូវ៣៩៥-៦៥៦, សង្កាត់ទឹកល្អក់៣, ខណ្ឌទួលគោក,រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ៖ ០២៣ ៨៨៣ ៤២៧

I https://gda.maff.gov.kh/
F https://www.facebook.com/gda.maff.gov.kh

**Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH**

ការិយាល័យចុះបញ្ជី៖
Bonn and Eschborn, Germany

គម្រោង៖ ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ នៅអាស៊ី (SRECA)

*នៅកម្ពុជា៖*

ការិយាល័យ GIZ ASEAN Regional Economic Integration, មជ្ឈមណ្ឌលពាណិជ្ជកម្ម Delano ជាន់ទី៧, មហាវិថីសាធារណៈឆែក (១៦៩), កែងផ្លូវលេខ ១៣៤, សង្កាត់វាលវង់, ខណ្ឌ៧មករា, ភ្នំពេញ (១២២៥៣), កម្ពុជា

*នៅប្រទេសចិន៖*

Tayuan Diplomatic Office Building 1-14-1
Liangmahe Nanlu No 14
Beijing 100600, Chaoyang District
T + 86 10 8532 1857 F + 86 10 8532 5774

E sreca@giz.de
I www.connecting-asia.org
I www.giz.de/en/worldwide/34101.html

**និពន្ធដោយ/ចងក្រងដោយ៖**
Nikolaus Schall

**អ្នកកែសម្រួល៖**
GIZ, GDA

**រចនា/រៀបចំ៖**
Nikolaus Schall

**កម្មសិទ្ធរូបភាព**
GDA
Alibaba.com (Packaging examples)
aam-sutra.blogspot.com (mango-packaging)

### សេចក្តីថ្លែងអំណរគុណ

ឯកសារណែនាំស្តីពីការនាំចេញផ្លែស្វាយស្រស់ចេញទៅកាន់ប្រទេសចិនត្រូវបានបង្កើតឡើងរួមគ្នាដោយ អគ្គនាយកដ្ឋានកសិកម្ម និងគម្រោង "ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ នៅអាស៊ី" (SRECA) អនុវត្តដោយទីភ្នាក់ងារអភិវឌ្ឍន៍ GIZ តំណាងអោយក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)។


### សេចក្តីអះអាង


ទស្សនៈ និងយោបល់ដែលបានលើកឡើងដោយអ្នកនិពន្ធនៅក្នុងសៀវភៅនេះមិនបានឆ្លុះបញ្ចាំង ឬបង្ហាញពីគំនិតរបស់ GIZ ឡើយ។ GIZ ទទួលខុសត្រូវលើខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ។ សៀវភៅណែនាំនេះត្រូវបានចងក្រងជាឧបករណ៍គាំទ្រ។ មិនមានការទទួលខុសត្រូវផ្នែកច្បាប់ណាមួយត្រូវបានទទួលយកសម្រាប់ការខូចខាតណាមួយដែលកើតឡើងពីព័ត៌មានមិនត្រឹមត្រូវនៅក្នុងសៀវភៅណែនាំនេះទេ។



ភ្នំពេញ ខែធ្នូ ឆ្នាំ២០២០

# មាតិកា


អំពីឯកសារនេះ ..... 1

1 ទិដ្ឋភាពរួមនៃការនាំចេញផ្លែស្វាយទៅកាន់ប្រទេសចិន ..... 2

1.1 ការណែនាំអំពីទីផ្សារផ្លែឈើរបស់ប្រទេសចិន ..... 2

1.2 គោលបំណងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការជំរុញការនាំចេញផ្លែឈើទៅកាន់ប្រទេសចិន ..... 2

1.3 ផលិតកម្មផ្លែស្វាយស្រស់ក្នុងប្រទេសកម្ពុជា ..... 4

1.4 ចំណូលចិត្ត និងរសជាតិស្វាយនៅប្រទេសចិន ..... 6

2 សាវតានៃគោលនយោបាយនាំចេញ និងនាំចូលផ្លែស្វាយកម្ពុជា និងចិន ..... 7

2.1 កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង អាស៊ាន-ចិន (ព្រមព្រៀងពាណិជ្ជកម្មសេរី FTA) ..... 7

2.2 ពិធីសារលក្ខខណ្ឌតម្រូវភូតគាមអនាម័យផ្លែស្វាយរវាងកម្ពុជា-ចិន ..... 8

2.3 គោលនយោបាយស្តីពីការនាំចូល និងនាំចេញទៅប្រទេសចិន ..... 9

2.4 កំពង់ផែនៅប្រទេសចិនដែលត្រូវបានរៀបចំជាកំពង់ផែផ្លែឈើ ..... 9

3 នីតិវិធីនាំចេញស្វាយម្តងមួយជំហាន ..... 12

3.1 ការចុះបញ្ជីកសិករដាំស្វាយ និងកន្លែងវេចខ្ចប់ជាមួយអគ្គនាយកដ្ឋានកសិកម្ម (GDA) ..... 12

3.2 វិញ្ញាបនបត្រ និងស្តង់ដារ ..... 12

3.2.1 ការធ្វើអធិការកិច្ច និងចត្តាឡីស័កមុនពេលនាំចេញ ..... 12

3.2.2 ការទទួលបានវិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ ..... 13

3.2.3 ការគ្រប់គ្រងចម្ការ ..... 16

3.2.4 ការពិនិត្យអនុលោមភាព ..... 16

3.3 ការប្រកាសពន្ធគយ និងឯកសារគាំទ្រ ..... 16

3.3.1 លក្ខខណ្ឌតម្រូវសម្រាប់ការវេចខ្ចប់ និងចត្តាឡីស័ក ..... 16

3.3.2 នីតិវិធីគយ/ការទទួលបានអាជ្ញាប័ណ្ណនាំចេញ ..... 17

3.3.3 វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ..... 17

3.4 ការដឹកជញ្ជូនផ្លែស្វាយ និងការទូទាត់ប្រាក់ ..... 18

3.4.1 ការរៀបចំផ្លែស្វាយសម្រាប់នាំចេញ ..... 18

3.4.2 ការវេចខ្ចប់ និងដាក់ស្លាកឈ្មោះផ្លែស្វាយ ..... 19

3.4.3 ការដឹកជញ្ជូនផ្លែស្វាយពីប្រទេសកម្ពុជាទៅប្រទេសចិន ..... 22

3.4.4 ការកសាង និងអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនដឹកជញ្ជូននាំចេញ ..... 23

3.4.5 ភ្នាក់ងារ និងអ្នកចែកចាយ ..... 24

3.4.6 នីតិវិធីទូទាត់ប្រាក់ ..... 26

4 លក្ខខណ្ឌតម្រូវដាក់លាក់សម្រាប់នាំចូលក្នុងប្រទេសចិន ..... 27

4.1 ច្បាប់ និងបទប្បញ្ញត្តិ.....28
4.1.1 ទិដ្ឋភាពទូទៅនៃបទប្បញ្ញត្តិ និងច្បាប់ និងតួនាទីរបស់ GACC.....28
4.1.2 ច្បាប់ និងបទប្បញ្ញត្តិសម្រាប់នាំចូលផ្លែឈើស្រស់.....30
4.2 ការធ្វើអធិការកិច្ច តេស្ត និងត្រួតពិនិត្យគុណភាព.....31
4.2.1 បញ្ជីឯកសារដែលត្រូវការសម្រាប់ការដឹកជញ្ជូនផ្លែឈើស្រស់ចូលមកប្រទេសចិន.....32
4.2.2 ឯកសារពិសេសសម្រាប់ផ្លែស្វាយពីប្រទេសកម្ពុជា.....33
4.3 ដំណើរការទូទាត់ចត្តាឡីស័ក និងពន្ធគយ.....33
4.4 ការធ្វើអធិការកិច្ចចត្តាឡីស័ក និងគយ និងនិតិវិធីនៃការធ្វើតេស្ត.....35
5 ការណែនាំសម្រាប់ផលិតកម្ម និងទីផ្សារស្វាយ.....37
5.1 ផលិតកម្មស្វាយ.....37
5.2 ការផ្តោតលើគុណភាព.....38
5.3 ការស្រាវជ្រាវទីផ្សារ.....38
5.4 ភាពជាដៃគូក្នុងស្រុក.....39
5.5 ការធ្វើទីផ្សារ និងការកសាងម៉ាកយីហោ.....39
5.6 ការធ្វើទីផ្សារ.....39
5.7 ការគ្រប់គ្រងហានិភ័យ.....40
6 បញ្ជីពិព័រណ៍ពាណិជ្ជកម្មពាក់ព័ន្ធនៅក្នុងប្រទេសចិន.....41
7 ឧបសម្ព័ន្ធ.....42
ឧបសម្ព័ន្ធទី ១៖ ជំហាន/ដំណើរការនៃការដាក់ពាក្យសុំវិញ្ញាបនប័ត្រភូតគាមអនាម័យ.....42
ឧបសម្ព័ន្ធទី ២៖ ការប្រកាសពន្ធគយ (កម្ពុជា).....43
ឧបសម្ព័ន្ធទី ៣៖ គំរូទម្រង់/ឯកសារសម្រាប់នាំចេញសំខាន់ៗ.....49
ឧបសម្ព័ន្ធទី ៤៖ ទីភ្នាក់ងាររដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា.....57
ឧបសម្ព័ន្ធទី ៥៖ បញ្ជីភ្នាក់ងារ និងអាជ្ញាធរនៅកម្ពុជា និងចិន.....61

# បញ្ជីឧបសម្ព័ន្ធ

1 : ជំហាន/ដំណើរការនៃការដាក់ពាក្យសុំវិញ្ញាបនបត្រភូតគាមអនាម័យ
2: ការប្រកាសពន្ធគយ (កម្ពុជា)
3: គំរូទម្រង់/ឯកសារសម្រាប់នាំចេញសំខាន់ៗ
4: ទីភ្នាក់ងាររដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធនានា
5: បញ្ជីភ្នាក់ងារ និងអាជ្ញាធរនៅកម្ពុជា និងចិន

# អំពីឯកសារនេះ

ការកើនឡើងប្រាក់ចំណូល និងជីវភាពប្រជាជនថ្នាក់កណ្ដាលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងតម្រូវការដែលមិនចេះរីងស្ងួតរបស់ប្រទេសចិននូវផ្លែឈើស្រស់ដែលដាំក្នុងស្រុក និងនាំចូលដែលមានគុណភាពខ្ពស់។ យោងតាមស្ថិតិផ្លូវការប្រាក់ឈ្នួលរបស់ប្រជាជននៅទីក្រុងប្រចាំឆ្នាំនៅប្រទេសចិនជាមធ្យមបានកើនឡើង១៦៥% ចន្លោះឆ្នាំ២០០៩ ដល់ ២០១៨ ពីប្រមាណ ៣២,២៤៤ យន់ (៤,៥៦៩ $) ទៅ ៨២,៤៦១ យន់ (១១,៦៨៤ $)។ ក្នុងរយៈពេលដូចគ្នា តម្លៃនៃការនាំចូលផ្លែឈើស្រស់របស់ចិនបានកើនឡើងជាង ៤៨៧% ពីក្រោម១,២ពាន់លានដុល្លារដល់ជាង ៦,៩ ពាន់លានដុល្លារ។ រដ្ឋាភិបាលចិនបានសម្របសម្រួលការរីកចម្រើនយ៉ាងឆាប់រហ័សក្នុងការនាំចូលទាំងនេះតាមរយៈការពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនាំចេញផ្លែឈើរួមមានតាមរយៈ ការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងការបង្កើនជាលំដាប់នូវចំនួនផ្លែឈើស្រស់ដែលអនុញ្ញាតឱ្យនាំចូលមកប្រទេសចិនបាន។ នៅក្នុងឆ្នាំ២០១៨ប្រទេសចិនបាននាំចូលផ្លែស្វាយស្រស់ជិត១១,០០០ តោន ដែលមានតម្លៃជាង ២០លានដុល្លារពីប្រទេស និងតំបន់ចំនួន៩ ដែលតំណាងឲ្យ ១១៣% នៃបរិមាណដែលកើនឡើង ប៉ុន្តែមានតែ ៨.១% នៃតម្លៃដែលបានកើនឡើងបើធៀបទៅនឹងឆ្នាំ២០១៧[1] ។ នៅខែមិថុនាឆ្នាំ ២០២០ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនតំណាងដោយរដ្ឋបាលគយ និងព្រះរាជាណាចក្រកម្ពុជាតំណាងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះហត្ថលេខាលើពិធីសារនៃលក្ខខណ្ឌតម្រូវផ្នែកភូតគាមអនាម័យសម្រាប់នាំចេញផ្លែស្វាយស្រស់ពីប្រទេសកម្ពុជាទៅប្រទេសចិន។ កិច្ចព្រមព្រៀងនេះបានត្រួសត្រាយផ្លូវសម្រាប់អ្នកផលិត និងអ្នកនាំចេញស្វាយរបស់កម្ពុជាក្នុងការនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន[2]។

គម្រោង "ការគាំទ្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ នៅអាស៊ី (SRECA)" ផ្តួចផ្តើមដោយក្រសួងសហព័ន្ធសម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) និងអនុវត្តដោយ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH ធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ឡាវ ម៉ុងហ្គោលី ចិន និងវៀតណាមក្នុងបរិបទនៃយន្តការសហប្រតិបត្តិការអនុតំបន់ដូចជា គំនិតផ្តួចផ្តើម Greater Tumen (GTI) នៅអាស៊ីខាងកើត ឬតំបន់ពាណិជ្ជកម្មសេរី អាស៊ាន-ចិន នៅតំបន់អាស៊ាន។ ឆ្លើយតបទៅនឹងតម្រូវការរបស់សហគ្រាសកម្ពុជា GIZ បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការផ្តល់សៀវភៅណែនាំស្តីពីការនាំចេញ ផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិន ដើម្បីជួយសម្រួលដល់ការសម្របសម្រួលពាណិជ្ជកម្មរវាងប្រទេសទាំងពីរជាពិសេសសម្រាប់អ្នកនាំចេញ។ ផ្លែស្វាយស្រស់នេះមានសក្តានុពលទីផ្សារនាំចេញទៅកាន់ប្រទេសចិន។

សៀវភៅណែនាំស្តីពីការនាំចេញផ្លែស្វាយស្រស់ទៅកាន់ប្រទេសចិននេះ គឺជាគោលការណ៍ណែនាំលម្អិតសម្រាប់សហគ្រាសឯកជននៅកម្ពុជាដែលមានបំណងនាំចេញផលិតផលរបស់ពួកគេទៅកាន់ប្រទេសចិន។

---

1 Tropical Fresh Fruit Exporter's Guide to China, March 2020, Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Support of Regional Economic Cooperation in Asia (SRECA), Cambodia

2 China-Cambodia Protocol on Phytosanitary Requirements for the export of fresh Mango from Cambodia to China

# 1 ទិដ្ឋភាពរួមនៃការនាំចេញផ្លែស្វាយទៅកាន់ប្រទេសចិន

## 1.1 ការណែនាំអំពីទីផ្សារផ្លែឈើរបស់ប្រទេសចិន

ប្រទេសចិនគឺជាប្រទេសផលិត នាំចូល និងប្រើប្រាស់ផ្លែឈើស្រស់ដ៏ធំបំផុតនៅលើពិភពលោក។ កំណើនសេដ្ឋកិច្ច និងប្រាក់ឈ្នួលមធ្យមប្រចាំឆ្នាំរបសប្រជាជនចិនក្នុងទីក្រុងបានកើនឡើងយ៉ាងលឿនពីជាង ៤,៥០០$ ក្នុងឆ្នាំ ២០០៩ ដល់ជាង១១,០០០$ ក្នុងឆ្នាំ២០១៨[3]។ អ្នកបរិភោគ/អ្នកប្រើប្រាស់នៅប្រទេសចិនមានធនធានច្រើនដើម្បីចំណាយ និងកំពុងយល់ដឹងអំពីបញ្ហាសុខភាពកាន់តែច្រើនឡើង។ ការលក់ផ្លែឈើស្រស់បានក្លាយជាលក្ខណៈសំខាន់មួយនៅទីផ្សារប្រទេសចិន។ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ តម្លៃនៃការនាំចូលផ្លែឈើស្រស់របស់ចិនបានកើនឡើងពីក្រោម ១,២ ពាន់លានដុល្លារក្នុងឆ្នាំ ២០០៩ ដល់ជាង ៦,៩ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៨ ដោយមានផ្លែឈើជាង ២០០ ប្រភេទមកពី ២៤ ប្រទេសត្រូវបានអនុញ្ញាតឱ្យនាំចូលក្នុងឆ្នាំ២០១៩។ នៅក្នុងឆ្នាំ ២០១៨ ប្រទេសចិនបាននាំចូលផ្លែស្វាយស្រស់ជិត ១១,០០០ តោន ជាមួយតម្លៃជាង ២០ លានដុល្លារពីប្រទេស និងតំបន់ចំនួន៩ ដែលតំណាងឲ្យ ១១៣% នៃបរិមាណដែលកើនឡើង ប៉ុន្តែមានតែ ៨.១% នៃតម្លៃដែលបានកើនឡើងបើធៀបទៅនឹងឆ្នាំ ២០១៧[4]។ ការកើនឡើងទាំងនេះដោយសារប្រទេសថៃ និងវៀតណាមដែលបានបង្កើនបរិមាណនៃការនាំចេញផ្លែស្វាយទៅកាន់ប្រទេសចិនបានកើនឡើងពី ៤៩២% ទៅ ៨១៦% រៀងៗខ្លួន។ ផ្លែស្វាយត្រូវបានគេបរិភោគនៅទូទាំងប្រទេសចិន ទោះបីការប្រើប្រាស់ច្រើនបំផុតនៅតំបន់ភាគខាងត្បូងក៏ដោយ។ លើសពីនេះទៀតផ្លែស្វាយក្នុងស្រុកមួយចំនួនធំរបស់ចិនត្រូវបានកែច្នៃជាទឹកផ្លែឈើ ស្វាយស្ងួត និងផលិតផលផ្សេងទៀត[5]។

## 1.2 គោលបំណងរបស់រដ្ឋាភិបាលកម្ពុជាក្នុងការជំរុញការនាំចេញផ្លែឈើទៅកាន់ប្រទេសចិន

ប្រទេសកម្ពុជា គឺជាទីផ្សារដ៏ទាក់ទាញសម្រាប់វិនិយោគិនបរទេស ជាពិសេសមកពីប្រទេសចិនដោយសារតែទីតាំងភូមិសាស្ត្រ និងគោលនយោបាយវិនិយោគដែលមានលក្ខណៈអំណោយផល។ ស្របពេលជាមួយគ្នានេះ កម្ពុជាត្រូវតែចាប់យកឱកាសទីផ្សារនេះ និងខិតខំពង្រីកបរិមាណនាំចេញផលិតផលកសិកម្មដើម្បីជួយបង្កើនកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាមានចាប់អារម្មណ៍យ៉ាងខ្លាំងក្នុងការគាំទ្រដល់អ្នកដាំផ្លែឈើ និងអ្នកនាំចេញចូលទៅកាន់ផ្សារអន្តរជាតិដើម្បីបង្កើនបរិមាណនៃការនាំចេញផ្លែឈើ ដោយសារប្រទេសចិនគឺជាទីផ្សារសំខាន់សម្រាប់ការនាំចេញផ្លែស្វាយរបស់កម្ពុជា។ សេចក្តីសង្ខេបអំពីភ្នាក់ងារសំខាន់ៗរបស់រដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការនាំចេញផ្លែឈើត្រូវបានបញ្ចូលក្នុងឧបសម្ព័ន្ធទី ៤នៃឯកសារនេះ។

---

[3] Markets for Cambodian Crops with Promising Prospects, Bastiaan Bijl Consultancy GMBH, on behalf of CAVAC, May 2020

[4] **Note:** There are some distortion in these growth figures as mango and other fruits are also often traded across the border (= grey market exports), with Cambodian mango being traded via Vietnam border. As a result, they are classified as Vietnamese exports and not Cambodia. However, as the border inspection become stricter, some border trade has changed over to becoming "normal" legal trade. This is the main reason why the export volume soared in 2018.

[5] Tropical Fresh Fruit Exporter's Guide to China, March 2020, Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Support of Regional Economic Cooperation in Asia (SRECA), Cambodia

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចែងគោលនយោបាយ និងបទប្បញ្ញត្តិជាច្រើនសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម និងការនាំចេញផលិតកសិកម្មជាក់លាក់។ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍថ្នាក់ជាតិ ២០១៩-២០២៣ ជាគោលនយោបាយរួមបញ្ចូលថ្នាក់ជាតិពីរដែលលំអិតអំពីគោលដៅក្នុងការពង្រីកការអភិវឌ្ឍន៍នូវគ្រប់អនុវិស័យកសិកម្មតាមរយៈការបង្កើនផលិតភាព ការធ្វើទំនើបកម្ម និងពាណិជ្ជកម្ម។ ការអភិវឌ្ឍន៍វិស័យកសិកម្មនៅក្នុងប្រទេសកម្ពុជាត្រូវបានគូសបញ្ជាក់នៅក្នុងផែនការយុទ្ធសាស្រ្តវិស័យកសិកម្ម ២០១៩-២០២៣ និងផែនការមេសម្រាប់វិស័យកសិកម្ម ២០៣០ ដែលមានបំណងលើកកម្ពស់ការប្រកួតប្រជែង កំណើនប្រកបដោយបរិយាប័ន្ន និងវិស័យកសិកម្មទំនើបប្រកបដោយចីរភាព និងភាពបត់បែន[6] ។

ជាក់ស្តែង នៅក្នុងអនុវិស័យដំណាំ ផែនការមេសម្រាប់ផលិតកម្មដំណាំឆ្នាំ ២០១៦-២០៣០ ប្រមើលមើលថាប្រទេសកម្ពុជាជាប្រភពដែលជឿជាក់បាននៃកសិផលដែលមានគុណភាពខ្ពស់ សុវត្ថិភាព និងការប្រកួតប្រជែងនៅក្នុងសេដ្ឋកិច្ចពិភពលោកដោយធានាបាននូវបរិមាណអាហារដែលមានសុវត្ថិភាពគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងអសន្តិសុខស្បៀងនិងអាហារូបត្ថម្ភរបស់ពលរដ្ឋរបស់ខ្លួនប្រកបដោយនិរន្តរភាព និងភាពធន់ទៅនឹងអាកាសធាតុ។ នៅក្រោមផែនការមេដំណាំអាទិភាពចំនួន៨មុខ និងខ្សែច្រវ៉ាក់តម្លៃរបស់វាត្រូវបានកំណត់សម្រាប់ធ្វើការបញ្ជាក់បន្ថែមទៀតសម្រាប់ការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ។ ស្វាយជាដំណាំមួយក្នុងចំណោមដំណាំដែលត្រូវបានជ្រើសរើស ហើយមានចក្ខុវិស័យច្បាស់លាស់សម្រាប់ឆ្នាំ ២០៣០ *"កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនាំចេញស្វាយស្រស់ទាំង៥ ដែលមានគុណភាពល្អលើពិភពលោក។"*

ដោយដឹងអំពីសារៈសំខាន់ និងការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់អនុវិស័យសាកវប្បកម្ម រដ្ឋាភិបាលកំពុងបង្កើតយុទ្ធសាស្រ្តសាកវប្បកម្មដែលគ្របដណ្តប់លើផ្នែកទាំង ៨ រួមមាន ការស្រាវជ្រាវនិងអភិវឌ្ឍន៍(R&D) ការកែលំអផលិតកម្មនិងផលិតភាព ការគ្រប់គ្រងក្រោយប្រមូលផល ទីផ្សារនិងការនាំចេញ ការកែច្នៃនិងបន្ថែមតម្លៃ ការអភិវឌ្ឍធនធានមនុស្ស ក្រុមអ្នកផលិតនិងក្រុមអ្នកប្រើប្រាស់ និងការសហការនិងភ្ជាប់បណ្តាញជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត។

នៅកម្រិតផលិតកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម និងអនុក្រឹត្យស្តីពីការធ្វើកសិកម្មតាមកិច្ចសន្យាមានគោលបំណងដើម្បីពង្រឹងទំនួលខុសត្រូវ និងកសាងការជឿទុកចិត្តរវាងកសិករ និងអ្នកទិញដោយផ្អែកលើគោលការណ៍"សមភាព និងយុត្តិធម៌"។ បែបបទនៃការធ្វើកសិកម្មតាមកិច្ចសន្យា គឺដើម្បីធានាបាននូវតម្លៃ គុណភាពនិងបរិមាណនៃការផ្គត់ផ្គង់ផលិតផលកសិកម្ម និងដើម្បី"បង្កើនការទិញ ការកែច្នៃ និងការនាំចេញផលិតផលកសិកម្ម"។ យោងតាមអនុក្រឹត្យនេះ កសិករធ្វើការដោយផ្ទាល់ជាមួយអ្នកទិញក្រោមការសម្របសម្រួលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ លើសពីនេះទៅទៀត ប្រកាសស្តីពីការអនុវត្តន៍កសិកម្មល្អ(GAP) ក៏ត្រូវបានអនុម័តដោយផ្អែកលើស្តង់ដារ GAP របស់តំបន់អាស៊ានដោយបានណែនាំវិញ្ញាបនប័ត្រកម្ម GAP ដែលត្រូវបានផ្តល់ទៅឲ្យចម្ការបន្លែ ផ្លែឈើ និងកសិដ្ឋានកសិកម្មដទៃទៀតដែលត្រូវបានចុះបញ្ជី។ រហូតមកដល់បច្ចុប្បន្ននេះ មានចម្ការចំនួន ៥០ ត្រូវបានចុះបញ្ជីនៅប្រទេសកម្ពុជាដែលភាគច្រើនជាចម្ការផ្លែឈើ។ គោលនយោបាយផ្សព្វផ្សាយកសិកម្មដែលត្រូវបានអនុវត្តតាំងពីឆ្នាំ ២០១៥មកមាន

[6] Source: GIZ; Mapping Actors in Trade/Export of Agriculture Produce in Cambodia, 31 July 2020, BDTrus consultancy

គោលបំណងជួយកសិករឱ្យទទួលបានចំណេះដឹង ជំនាញ ព័ត៌មាន និងបច្ចេកវិទ្យាកាន់តែច្រើនដើម្បីលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជកម្មកសិកម្ម។

ពិធីសារចិន-*កម្ពុជាស្តីពីលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចេញស្វាយស្រស់ពី ប្រទេសកម្ពុជាទៅកាន់ប្រទេសចិន"* ដែលបានចុះហត្ថលេខាកាលពីពេលថ្មីៗនេះ គឺជាឧទាហរណ៍ដ៏ល្អមួយដែលបង្ហាញថារដ្ឋាភិបាលបានសម្របសម្រួល និងគាំទ្រដល់អ្នកដាំដុះ និងអ្នកនាំចេញដើម្បីចូលទៅទីផ្សារចិន។

## 1.3 ផលិតកម្មផ្លែស្វាយស្រស់ក្នុងប្រទេសកម្ពុជា

ឈ្មោះវិទ្យាសាស្ត្ររបស់ស្វាយគឺ Mangifera indica ហើយវាត្រូវបានដាំនៅក្នុងតំបន់ពាក់កណ្តាលត្រូពិក និងតំបន់ត្រូពិករួមទាំងប្រទេសកម្ពុជាផងដែរ[7]។ មានប្រភេទពូជស្វាយជាច្រើនដែលខុសគ្នាទៅតាមលក្ខខណ្ឌដី និងអាកាសធាតុ។ នៅប្រទេសកម្ពុជា ប្រភេទពូជស្វាយដែលដាំដុះច្រើនជាងគេ គឺស្វាយកែវរមៀតដែលមានទំហំធំសំបកពណ៌លឿងស្រាលមានកម្រិតសរសៃពីមធ្យមទៅទាប និងមានក្លិនក្រអូបស្រាលជាមួយនឹងរសជាតិផ្អែមល្ហម។

ប្រទេសកម្ពុជាកំពុងតែទទួលបានជោគជ័យក្នុងការផលិតកម្ម និងនាំចេញផ្លែស្វាយស្រស់។ បច្ចុប្បន្នផ្ទៃដីសរុបសម្រាប់ចម្ការស្វាយនៅកម្ពុជាមានលើសពី ១២៤,៣ ពាន់ហិកតា។ បរិមាណផលិតកម្មប្រចាំឆ្នាំឈានដល់ ១,៤៤ លានតោន[8]។ កម្ពុជាបានសម្រេចបានបរិមាណនាំចេញផ្លែស្វាយស្រស់ដែលមានគុណភាពល្អ ហើយកំពុងបង្កើនចំណែកទីផ្សារ និងចាប់យកទីផ្សារថ្មីៗ។ លទ្ធភាពនៃការនាំចេញផ្លែស្វាយស្រស់ទៅកាន់ទីផ្សារប្រទេសចិនគឺជាឱកាសដ៏មានតម្លៃសម្រាប់កសិករដាំស្វាយនៅកម្ពុជា។ កត្តានេះនឹងជួយដល់សេដ្ឋកិច្ចកម្ពុជា និងបង្កើនការអភិវឌ្ឍន៍ភូមិកសិកម្មបន្ថែមទៀតនៅក្នុងតំបន់ដែលកំពុងអភិវឌ្ឍ។ ក្រុមហ៊ុនចំនួន ២៩ សហគមន៍កសិកម្មចំនួន ៣ និងកសិករចំនួន ១១ នាក់បានដាក់ពាក្យសុំការអនុញ្ញាតនាំចេញផ្លែស្វាយស្រស់រួចហើយ។ ផ្នែកស្វាយស្ងួត ក៏កំពុងរីកលូតលាស់យ៉ាងឆាប់រហ័សដោយមានកន្លែងកែច្នៃថ្មីៗកំពុងត្រូវបានបង្កើតឡើង។

---

[7] According to the research, mangoes are named as of different varieties in Cambodia as follows: Svay Kev Chin, Kev Lor Miet, Kev Sa Ry, Kev Lor Mut, Kev Pong Maon, Kev Moung, Kev Srouch, Kev Thlong, Kev Phum Sen, Svay Kbal Damrey, Svay Paom, Svay Yak, Svay Kiev Sang Ve, Kev La Hong, Kro Horm, Kev Leak, Svay Khtis Dong, Svay Ma Kak

[8] Source: https://english.cambodiadaily.com/business/cambodia-signs-mango-export-agreement-with-china-165496/

**រូបភាពទី ១៖ ប្រភេទស្វាយកែវរមៀតដែលបាននាំចេញពីប្រទេសកម្ពុជាទៅប្រទេសចិន**



អគ្គនាយកដ្ឋានកសិកម្ម (នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)[9] បានធ្វើការសាកល្បងរយៈពេល ៣ ឆ្នាំលើពូជស្វាយដែលបាននាំចូលហើយបានអនុញ្ញាតលើភាពសមស្របនៃអាកាសធាតុ និងដីកម្ពុជាសម្រាប់ប្រភេទពូជស្វាយដូចខាងក្រោម[10]៖

| | | | |
|---|---|---|---|
| • Guire #82 | • Irwin | • Jinh Wang, Xishi | • Narissus Mango |
| • Tainon #1 | • Shan Lin | • Red Golden Dragon | • Sensation |
| • R2E2 | • Yuwin #6 | • Renong #1 | |
| • Keitt | • Three Years | • Jinh Wang, Xishi | |

រហូតមកដល់ពេលនេះ មានកសិដ្ឋានធំមួយនៅក្នុងប្រទេសកម្ពុជាដែលត្រូវបានគេរាយការណ៍ថាបានដាំពូជស្វាយថ្មីៗទាំងនេះរួមមាន Keitt និង R2E2 ។ នៅក្នុងប្រទេសចិន R2E2 មានតម្លៃថ្លៃដោយសារពណ៌បៃតង ជាមួយនឹងពណ៌ក្រហមភ្លឺរបស់វា ប៉ុន្តែប្រភេទដែលពេញនិយមនៅប្រទេសចិនគឺស្វាយកែវរមៀត។

សម្រាប់អ្នកផលិត និងអ្នកនាំចេញ ការដាំពូជស្វាយប្រភេទខុសៗគ្នាសម្រាប់ការនាំចេញអាចទទួលបានអត្ថប្រយោជន៍ជាច្រើនក្រោមហេតុផលមួយចំនួនដូចជា៖ **ក**) ផ្លែស្វាយអាចត្រូវបាននាំចេញក្នុងកំឡុងខែដែលប្រទេសផ្សេងទៀតមិនអាចនាំចេញទៅប្រទេសចិនបាន **ខ**) ប្រភេទពូជខុសៗគ្នាក៏អាចមានភាពខុសគ្នាបន្តិចបន្តួចក្នុងពេលវេលាប្រមូលផល ដែលអាចមានអត្ថប្រយោជន៍ដល់ការគ្រប់គ្រងការចែកចាយផលិតផលស្រស់ជាពិសេសជាមួយរដូវដ៏ខ្លីដូចស្វាយកែវរមៀត។ ពូជខ្លះដូចជា Tommy Atkins ទុំនៅដើមរដូវក្នុងអំឡុងខែ តុលា/វិច្ឆិកា ហើយ Keit និង Kent ទុំនៅចុងខែកុម្ភៈ/មីនា។

[9] As per GDA's Department of Subsidiary Crops these are the imported varieties adopted for exporting purpose.
[10] Markets for Cambodian Crops with Promising Prospects, Bastiaan Bijl Consultancy GMBH, on behalf of CAVAC, May 2020

ប្រតិទិនខាងក្រោមផ្តល់នូវទិដ្ឋភាពរួមនៃរដូវនាំចេញផ្លែស្វាយទៅកាន់ប្រទេសចិនពីប្រទេសនាំចេញផ្លែស្វាយសំខាន់ៗ។

### ក្រាហ្វិកទី១៖ កាលវិភាគប្រចាំឆ្នាំនៃការផលិតកម្ម/ការនាំចូលផ្លែស្វាយទៅកាន់ប្រទេសចិន (រួមទាំងប្រទេសកម្ពុជា)

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កម្ពុជា | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | | | | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច |
| ថៃ | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច |
| ប៉េរូ | ផ្គត់ផ្គង់ច្រើន | | | | | | | | | | | ផ្គត់ផ្គង់ច្រើន |
| អូស្ត្រាលី | ផ្គត់ផ្គង់ច្រើន | | | | | | | | | | | ផ្គត់ផ្គង់ច្រើន |
| តៃវ៉ាន់ | | | | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | | | | | |
| ចិន | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់តិច | | ផ្គត់ផ្គង់តិច |
| វៀតណាម | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន | | | | | ផ្គត់ផ្គង់តិច | ផ្គត់ផ្គង់ច្រើន | ផ្គត់ផ្គង់ច្រើន |

ប្រភព៖ TradeMap និង ប្រភពគេហទំព័រផ្សេងៗទៀត គន្លឹះ៖ ផ្គត់ផ្គង់ច្រើន ផ្គត់ផ្គង់តិច

### ក្រាហ្វិកទី២៖ វដ្តប្រមូលផលនៃប្រភេទស្វាយផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា

| ប្រភេទស្វាយ | ខែប្រមូលផលច្រើន | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ១. កែវរមៀត | | | ១ | ១ | ១ | | | | | | | |
| | | | | | | | | | ២ | ២ | ២ | |
| | ៣ | ៣ | | | | | | | | | | ៣ |
| ២. កែវចិន | ១ | ១ | ១ | ១ | ១ | ១ | ១ | | | | | |
| ៣ .ស្វាយថៃ | | | | | | ១ | ១ | ១ | ១ | | | |
| ៤. កែវ | ១ | ១ | ១ | ១ | ១ | | | | | | | |
| ៥. ពុំសែន | ១ | ១ | ១ | | | | | | | | | |
| ៦. ខ្ទិះ | | ១ | ១ | | | | | | | | | |
| ៧. ខ្ទិះធូរេន | | | | | ១ | | | | | | | |

**សំគាល់កែវរមៀត៖** ១=ស្វាយប្រមូលផលតាមរដូវ ២= ស្វាយប្រមូលផលខុសរដូវទី ១ ៣=ស្វាយប្រមូលផលខុសរដូវទី ២

**ប្រភព៖** ទីផ្សារសម្រាប់ដំណាំនៅប្រទេសកម្ពុជាដោយទទួលបានជោគជ័យBastiaan Bijl,CAVAC, ខែមេសា ២០២០ ទំព័រ ៥

## 1.4 ចំណូលចិត្ត និងរសជាតិស្វាយនៅប្រទេសចិន

ប្រភេទពូជស្វាយ R2E2 ទំនងជាប្រភេទស្វាយដែលត្រូវនឹងទីផ្សារប្រទេសចិន។ ដូច្នេះប្រជាជនកម្ពុជាត្រូវសម្រេចចិត្តថាតើត្រូវដាំស្វាយកែវរមៀតឬ R2E2 ជាប្រភេទស្វាយស្រស់សម្រាប់នាំចេញទៅកាន់ប្រទេសចិន។ សូចនាករខ្លះអំពីចំណូលចិត្តអតិថិជនចិនក្នុងការជ្រើសរើសទិញផ្លែស្វាយរួមមាន៖

- ពណ៌ រសជាតិ និងភាពទុំរបស់ស្វាយ៖ ជារួម ពណ៌ត្រូវបានកំណត់ថាជាលក្ខណៈសំខាន់បំផុតក្នុងការជ្រើសរើសប្រភេទផ្លែស្វាយដែលល្អបំផុតដោយសារវាមានពណ៌លឿង/ទឹកក្រូចលាយពណ៌ក្រហមស្រាល។ អតិថិជនចិនចូលចិត្តទិញស្វាយនៅពេលវាទុំ ហើយសភាពទុំរបស់ស្វាយត្រូវបានកំណត់តាមរយៈការស្ទាប ពណ៌ និងក្លិនរបស់វា។ អាជីវករមួយចំនួននៅផ្សារលក់ដុំ កាងស៊ូជាំងណាន (Gangzou Jiangnan) បានចាត់ថ្នាក់ និងវេចខ្ចប់ម្តងទៀតទៅតាមសមាមាត្រនៃពណ៌របស់ស្វាយ ហើយចាប់ពីដំណាក់កាលនេះទៅ ស្វាយត្រូវបានបញ្ចូលទៅក្នុងខ្សែច្រវ៉ាក់ចែកចាយត្រជាក់ តែមិនជាក់រហូតនោះទេសម្រាប់ផ្លែស្វាយដែលត្រូវចែកចាយបន្តទៅកាន់ទីក្រុងតូចៗ។
- ការលក់ផ្លែឈើស្រស់តាមអ៊ិនធឺណិត គឺជាបណ្តាញដ៏សំខាន់បំផុតសម្រាប់ការលក់នៅក្នុងប្រទេសចិន។ ទោះបីជាអ្នកលក់រាយតាមអ៊ិនធឺណិតជារឿយៗអះអាងថា ពួកគេបានបង្កើតខ្សែច្រវ៉ាក់ផ្គត់ផ្គង់ត្រជាក់ក៏ដោយ តាមពិតមានតែអ្នកលក់តិចតួចប៉ុណ្ណោះទេដែលមានបរិក្ខាបែបនេះ។ ជាលទ្ធផល ការលក់ផ្លែស្វាយភាគច្រើនតាមរយៈអ្នកលក់ដុំ។
- អ្នកនាំចូល និងអ្នកលក់ដុំចូលចិត្តធ្វើការជាមួយអ្នកផ្គត់ផ្គង់មួយចំនួនតូចប៉ុណ្ណោះ ដូច្នេះពួកគេអាចគ្រប់គ្រងការផ្គត់ផ្គង់ឱ្យបានទៀងទាត់។

# 2 សារតានៃគោលនយោបាយនាំចេញ និងនាំចូលផ្លែស្វាយកម្ពុជា និងចិន

## 2.1 កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង អាស៊ាន-ចិន (ព្រមព្រៀងពាណិជ្ជកម្មសេរី FTA)

ប្រទេសកម្ពុជា និងចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ដោយជោគជ័យកាលពីថ្ងៃទី ៥ ខែតុលាឆ្នាំ២០២០។ កិច្ចព្រមព្រៀងនេះផ្តល់លទ្ធភាពកាន់តែទូលំទូលាយដល់ប្រទេសកម្ពុជាក្នុងការចូលទៅកាន់ទីផ្សារ។ លើសពីនេះទៀត ទំហំពាណិជ្ជកម្ម និងការវិនិយោគរវាងប្រទេសទាំងពីរនឹងត្រូវបានពង្រីកបន្ថែមទៀត។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយសម្រាប់ប្រទេសកម្ពុជាក្នុងការចូលរួមកាន់តែស៊ីជម្រៅជាមួយប្រទេសចិនទាក់ទងនឹងការជំរុញពាណិជ្ជកម្មទ្វេភាគី និងការវិនិយោគផ្ទាល់ពីបរទេស (FDI)។ មានអត្ថប្រយោជន៍សំខាន់ពីរដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនឹងផ្តល់ឲ្យប្រទេសកម្ពុជារួមបញ្ចូលអ្នកនាំចេញស្វាយ។ ទីមួយ សេដ្ឋកិច្ចដែលរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា ហើយជាពិសេសការនាំចេញផលិតផលកសិកម្មនឹងទទួលបានអត្ថប្រយោជន៍ចាប់ពីការទទួលបានទីផ្សារថ្មីៗទៅកាន់ទីផ្សារដែលកំពុងកើនឡើងនៅក្នុងប្រទេសចិន។ ទីពីរ កិច្ចព្រមព្រៀងនឹងជំរុញលំហូរពាណិជ្ជកម្ម និងការវិនិយោគកាន់តែខ្លាំងឡើងរវាងកម្ពុជា និងចិនតាមរយៈការកាត់បន្ថយ ឬការដកចេញរបាំងពន្ធ ឬមិនមែនរបាំងពន្ធ។ ពុំមានការបង់ពន្ធនាំចូលផ្លែឈើស្រស់ចូលទៅកាន់ប្រទេសចិនទេតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន។ នៅទីបំផុតប្រទេសកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីផលិតផលចម្រុះ និងមានតម្លៃទាបជាងមុនសម្រាប់នាំចូលទីផ្សារក្នុងស្រុក។ ស្របពេលជាមួយគ្នានេះ ពាណិជ្ជកម្ម និងការវិនិយោគនឹងផ្តល់ឱ្យអ្នកប្រើប្រាស់ និងអាជីវកម្មផ្សេងៗនូវលទ្ធភាពទទួលបានទំនិញ និងសេវាកម្មដែលមានតម្លៃសមរម្យ។ ពាណិជ្ជកម្ម និងការវិនិយោគនឹងជំរុញកំណើនសេដ្ឋកិច្ចបន្តទៀត ដែលនឹងជួយប្រទេសកម្ពុជាឱ្យសម្រេចគោលដៅរបស់ខ្លួនក្នុងការក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។

អត្ថប្រយោជន៍ដែលគេរំពឹងទុកសម្រាប់ប្រទេសចិន គឺជួយប្រទេសចិនពង្រឹងចំណងទាក់ទងរបស់ខ្លួនជាមួយប្រទេសកំពុងអភិវឌ្ឍផ្សេងទៀតរួមទាំងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាទទួលបានអត្រាកំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ។ វាក៏នឹងជួយលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចដ៏ទូលំទូលាយបន្ថែមទៀតនៅក្នុងតំបន់ ហើយនឹងអនុញ្ញាតឱ្យក្រុមហ៊ុនចិនដើរតួនាទីកាន់តែសកម្មនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ដែលមានទំនាក់ទំនងនយោបាយ និងសេដ្ឋកិច្ចរឹងមាំជាមួយប្រទេសចិន។

សារៈសំខាន់គឺ សម្រាប់ប្រទេសកម្ពុជាក្នុងការត្រៀមខ្លួនរួចរាល់ដើម្បីពង្រីកឱកាសដែលកើតមានឡើងពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ដើម្បីកាត់បន្ថយហានិភ័យ និងបញ្ហាធំៗឲ្យស្ថិតនៅកម្រិតទាបបំផុត ហើយបញ្ហាដែលប្រទេសកម្ពុជាអាចប្រឈមតាមរយៈ លទ្ធផលនៃការបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះជាមួយប្រទេសមហាអំណាចសេដ្ឋកិច្ចចិន។ ពាណិជ្ជកម្មកម្ពុជាជាពិសេសសហគ្រាសធុនតូច និងមធ្យមចាំបាច់ត្រូវមានភាពសកម្មជាងមុនក្នុងការស្វែងរកធនធាន ការរៀបចំដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ការស្រាវជ្រាវឱ្យបានម៉ត់ចត់លើឱកាស និងបញ្ហាប្រឈមនានាព្រមទាំងជានាបាននូវការកែលម្អគុណភាព ការប្រកួតប្រជែង និងផលិតភាពរបស់ផលិតផល។ រដ្ឋាភិបាលកម្ពុជាត្រូវតែរៀបចំបង្កើតបរិយាកាសធុរកិច្ច ដែលមានលក្ខណៈអំណោយផលនៅក្នុងប្រទេសតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត លើកស្ទួយសេដ្ឋកិច្ចឌីជីថល និងអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុរបស់ខ្លួន។

## 2.2 ពិធីសារលក្ខខណ្ឌតម្រូវភូតគាមអនាម័យផ្លែស្វាយរវាងកម្ពុជា-ចិន

ពិធីសារស្តីពីលក្ខខណ្ឌភូតគាមអនាម័យសម្រាប់ផ្លែស្វាយត្រូវបានចុះហត្ថលេខានៅខែមិថុនា ឆ្នាំ ២០២០ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) នៃព្រះរាជាណាចក្រកម្ពុជា និងអគ្គរដ្ឋបាលគយ (GACC)នៃសាធារណរដ្ឋប្រជាមានិតចិន។

ពិធីសារនេះកំណត់ពីរបៀបដែលផ្លែស្វាយស្រស់ ដែលនឹងត្រូវនាំចេញទៅកាន់ប្រទេសចិនពីប្រទេសកម្ពុជាគួរតែត្រូវបានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធរបស់ប្រទេសចិន ត្រូវតាមលក្ខខណ្ឌតម្រូវការផ្នែកភូតគាមអនាម័យ និងមិនមានកត្តាចង្រៃដែលពាក់ព័ន្ធទៅដល់ប្រទេសចិន។ ពិធីសារនេះគ្របដណ្តប់តែលើលក្ខខណ្ឌតម្រូវផ្នែកភូតគាមអនាម័យតែប៉ុណ្ណោះ។ ស្តង់ដារ និងលក្ខខណ្ឌតម្រូវផ្សេងទៀតដែលពាក់ព័ន្ធនឹងសុខភាពមនុស្ស (ដូចជាស្តង់ដារសុវត្ថិភាពចំណីអាហាររបស់ប្រទេសចិន) ក៏អាចអនុវត្តបានលើផ្លែស្វាយមកពីប្រទេសកម្ពុជា ប៉ុន្តែមិនមានចែងក្នុងពិធីសារស្វាយដែលបានចុះហត្ថលេខានោះទេ។ ពិធីសារមិនទាក់ទងនឹងកូតានាំចេញ ឬប្រភេទពូជដែលត្រូវនាំចេញទេ។ ផ្នែកទាំងនេះ គឺជាការសំរេចចិត្តរបស់អ្នកផលិត និងអ្នកនាំចេញផ្លែស្វាយពីប្រទេសកម្ពុជា។

## 2.3 គោលនយោបាយស្តីពីការនាំចូល និងនាំចេញទៅប្រទេសចិន

នៅឆ្នាំ ២០១៨ អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក (AQSIQ) ត្រូវបានបញ្ចូលគ្នាទៅក្នុងអគ្គរដ្ឋបាលគយនៃសាធារណរដ្ឋប្រជាមានិតចិន (សូមមើលក្នុងផ្នែក៤.១ សម្រាប់មុខងារលម្អិតរបស់ GACC)។

សារៈសំខាន់សម្រាប់ការនាំចូលផ្លែឈើស្រស់ទៅកាន់ប្រទេសចិន គឺថាផ្លែឈើនេះស្ថិតនៅក្នុងបញ្ជីនៃការនាំចូលផ្លែឈើស្រស់នៅក្នុងប្រទេសចិន។ បញ្ជីផ្លូវការដែលត្រូវបានអនុញ្ញាតសម្រាប់ការនាំចូលនេះត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់អគ្គរដ្ឋបាលគយចិន (GACC) ប៉ុន្តែមានតែជាភាសាចិនប៉ុណ្ណោះ។ ភាសាអង់គ្លេសមាននៅលើតំណភ្ជាប់ខាងក្រោម https://www.producereport.com/market-access-list.

មិនមានពន្ធគយ ឬកូតានាំចូលលើផ្លែឈើដែលត្រូវបាននាំចេញពីកម្ពុជាទៅចិនទេ។ នេះគឺជាលទ្ធផលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់អាស៊ាន និងកិច្ចព្រមព្រៀងទ្វេភាគី។ ប៉ុន្តែអ្នកនាំចូលទៅប្រទេសចិនប្រហែលជាត្រូវ ដាក់ពាក្យសុំអនុញ្ញាតិកូតានាំចូល ដែលអ្នកនាំចូលក្នុងប្រទេសចិនបញ្ជាក់ពីបរិមាណដែលពួកគេចង់នាំចូល។ នៅពេលត្រូវបានយលស្រប អ្នកនាំចូលអាចនាំចូលផ្លែស្វាយជាបន្តបន្ទាប់រហូតដល់ចំនួនកូតាសរុបដែលបានអនុវត្ត និងត្រូវបានអនុញ្ញាតិក្នុងអាជ្ញាប័ណ្ណ។

## 2.4 កំពង់ផែនៅប្រទេសចិនដែលត្រូវបានរៀបចំជាកំពង់ផែផ្លែឈើ

ផ្លែស្វាយដែលត្រូវនាំចេញទៅប្រទេសចិននឹងត្រូវអនុញ្ញាតឱ្យចូលតាមកំពង់ផែផ្សេងៗដែលបានរៀបចំដោយ GACC សម្រាប់ការនាំចូលផ្លែឈើស្រស់។ កំពង់ផែចាំបាច់ត្រូវមានបរិក្ខាចាំបាច់ដើម្បីគ្រប់គ្រងការនាំចូលផ្លែឈើស្រស់[11]។ យោងតាមទិន្នន័យពីការិយាល័យអធិការកិច្ច និងចត្តាឡីស័កនៅឯច្រកចេញនៃការនាំចេញក្រុងសៀងហៃ ផ្លែឈើស្រស់ដែលនាំចូលមកកំពង់ផែនេះក្នុងឆ្នាំ ២០១៧ មានបរិមាណ១,០០៨,៨០០ តោន[12]។

កំពង់ផែសំខាន់ៗនៅប្រទេសចិនដែលទទួលផ្លែឈើរួមមាន៖ សៀងហៃ (Shanghai) ដាលៀន (Dalian) គីនចូវ (Qinzhou) សឹកគូ (Shekou) គីនហ័ងដាវ (Qinhuangdao) និងធៀនជីន (Tianjin)។

ឧទាហរណ៍ កំពង់ផែសឹកគូ(Shekou)គឺជាកំពង់ផែដ៏សំខាន់មួយនៅក្នុងស្រុក ដាវ៉ាន់(Dawan)។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមានគោលនយោបាយទូទាត់ (clearance) ពន្ធគយងាយស្រួល បរិក្ខាគាំទ្រល្អ និងសេវាកម្មប្រកបដោយប្រសិទ្ធភាព ក្រុមហ៊ុននាំចូលនិងនាំចេញកាន់តែច្រើនឡើងៗបានដឹងអំពីចំណុចខ្លាំងរបស់កំពង់ផែនេះ។ ប្រភេទ និងបរិមាណផ្លែឈើនាំចូលប្រទេសចិនឆ្លងកាត់កំពង់ផែសឹកគូបានកើនឡើងជារៀងរាល់ឆ្នាំ។ គោលដៅគឺធ្វើឲ្យ

---

11 China-Cambodia Protocol on Phytosanitary Requirements for the export of fresh Mango from Cambodia to China

12 https://www.freshplaza.com/article/187790/China-Annual-fruit-import-Shanghai-port-reaches-one-million-tons/

កំពង់ផែសឹកគូទៅជាកំពង់ផែនាំចូលផ្លែឈើធំជាងគេនៅភាគខាងត្បូងប្រទេសចិន។ ចាប់តាំងពីខែមេសា ឆ្នាំ ២០១៨ កំពង់ផែសឹកគូ បានចាប់ផ្តើមអនុវត្តគំរូទូទាត់ព័ន្ធគយដែលអនុញ្ញាតឱ្យក្រុមហ៊ុនប្រកាសពន្ធជាមុន និងទទួលបានទំនិញ ដឹកទំនិញចេញនៅពេលមកដល់ហុងកុង។ ចាប់តាំងពីឆ្នាំ ២០១៩ កំពង់ផែនេះបានចាប់ផ្តើមសាកល្បងគំរូទូទាត់ពន្ធគយការប្រកាសពន្ធពីរជំហាន(two-step declaration)។ បើនិយាយពីបរិក្ខាគាំទ្រ កំពង់ផែនេះមានទីតាំងត្រួតពិនិត្យ ចំនួន ១០៦កន្លែង និងមានកន្លែងទូទាត់ប្រាក់ចំនួន ៣១២៤ កន្លែង។ នៅឆ្នាំ២០១៨ ចំនួនកុងតឺន័រដែលចូលដល់កំពង់ផែសឹកគូមានសរុប ៤៦ ៣០០.TEU ដែលកើនឡើង ៤៣% បើប្រៀបធៀបទៅនឹងឆ្នាំមុន។ ផ្លែឈើដែលចូលតាមកំពង់ផែសឹកគូ(Shekou) ភាគច្រើនជាផ្លែស្រកានាគ ចេក ដូង មៀនប៉ៃលិន ម្នាស់ និងមង្ឃុត។

ឧទាហរណ៍មួយទៀតគឺកំពង់ផែគីនហ័ងដាវ (Qinhuangdao) គឺជាចំណុចសំខាន់នៃការនាំចូលផ្លែឈើស្រស់។ កំពង់ផែដែលបានរៀបចំសម្រាប់ផ្លែឈើនាំចូលនេះមានទីតាំងនៅជិតស្ថានីយកុងតឺន័រគីនហ័ងដាវ។ គម្រោងនេះរួមបញ្ចូលទាំងកន្លែងដាក់ទំនិញទំហំ ៣៦,០០០ ម$^{២}$ ដែលអាចផ្ទុកទូកុងតឺន័រត្រជាក់ស្តង់ដារបានចំនួន ៥០៤ មានកន្លែងធ្វើអធិការកិច្ចទំហំ ៣,០០០ម$^{២}$ (រួមមានកន្លែងធ្វើអធិការកិច្ច កន្លែងចត្តាឡីស័កទូកុងតឺន័រ និងកន្លែងជ្រើសរើសផ្លែឈើ) កន្លែងធ្វើចត្តាឡីស័កទំហំ ៣៦,០០០ម$^{២}$ (រួមមានកន្លែងសំលាប់/សម្អាតកត្តាចង្រៃ ដោយប្រើផ្សែង កន្លែងសំលាប់មេរោគដោយត្រជាក់ កន្លែងសំលាប់មេរោគដោយកំដៅ) ទីតាំងស្តុកទុកត្រជាក់ចំនួន២កន្លែងដែលមានទំហំសរុប ៦០០០ ម$^{៣}$ ដែលមានប្រព័ន្ធត្រួតពិនិត្យសីតុណ្ហភាព និងសំណើមស្វ័យប្រវត្តិ កន្លែងការិយាល័យ បន្ទប់ត្រួតពិនិត្យបឋម និងបន្ទប់ដាក់សំណាក។ កំពង់ផែគីនហ័ងដាវ ក៏កំពុងរៀបចំផែនការរៀបចំទីផ្សារលក់ដុំផ្លែឈើដែលនឹងគ្របដណ្តប់លើផ្ទៃដី៦ហិកតា។ បរិក្ខាសម្រាប់គាំទ្រទីផ្សារចែកចាយរួមមានឃ្លាំងស្តុក កន្លែងចតរថយន្ត សេវាកម្មការិយាល័យ និងសេវាផ្សេងទៀតត្រូវបានរៀបចំយ៉ាងពេញលេញសម្រាប់ផ្តល់នូវការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច បណ្តាញព័ត៌មាន ការធ្វើអធិការកិច្ចគុណភាព ការត្រួតពិនិត្យ ការកែច្នៃនិងចែកចាយ សេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មរួមផ្សេងទៀតសម្រាប់ទីផ្សារលក់ដុំដើម្បីផ្តល់ជូនប្រកបដោយសេវាកម្មជំនាញ រហ័ស និងមានគុណភាពខ្ពស់។

ហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូនតាមខ្សែច្រវ៉ាក់ត្រជាក់បានកើនឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសចិនដែលកើនឡើងពីឃ្លាំងស្តុកត្រជាក់ចំនួន ១០ លាន និងរថយន្តត្រជាក់១២,០០០គ្រឿងក្នុងឆ្នាំ ២០០៧ ដល់ ១០៦ លានឃ្លាំងស្តុកត្រជាក់ និង រថយន្តត្រជាក់៨៩,០០០ គ្រឿងក្នុងឆ្នាំ ២០១៥។ ការកើនឡើងយ៉ាងរហ័សនូវហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវ៉ាក់ត្រជាក់ត្រូវបានប្រមូលផ្តុំនៅក្នុងកំពង់ផែនាំចូលសំខាន់ៗ និងតំបន់ពាណិជ្ជកម្មសេរីដូចជា សៀងហៃ គ័ងចូវ (Guangzhou) ហ្វ៊ូជៀន(Fujian) និង ធានជីន (Tianjin)។ ជាមួយនឹងការកើនឡើងនៃពាណិជ្ជកម្មអេឡិចត្រូនិចនៅក្នុងទីផ្សារផ្លែឈើស្រស់ដែលនាំចូលទៅប្រទេសចិន ហានិភ័យពីមុនដែលទាក់ទងនឹងការទូទាត់ និងឥណទានដូចជាភាពមិនទុកចិត្តនៃការទូទាត់ពីអតិថិជនចិននិងអ្នកនាំចូល និងការពន្យារពេលក្នុងការទូទាត់ទាំងអស់ត្រូវបានកាត់បន្ថយតាមរយៈវិធីសាស្រ្តទូទាត់តាមអ៊ិនធឺណិតដែលមានការទទួលស្គាល់ទូលំទូលាយ ដោយភ្ជាប់ផ្ទាល់ទៅគេហទំព័រពាណិជ្ជកម្មផ្លែឈើស្រស់។ ដើម្បីទទួលបានប្រសិទ្ធភាព បង្ការការខូចខាត ចំណាយទាប និងភាពងាយស្រួលក្នុងការចូលប្រើជាទូទៅ អ្នកនាំចេញផ្លែឈើស្រស់ត្រូវបានផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ការនាំចេញដោយផ្ទាល់ជាបណ្តាញចែកចាយសំខាន់ៗ របស់ពួកគេទៅកាន់ប្រទេសចិនដីគោក។ មានទីផ្សារលក់ដុំជាង ៤០០០ កន្លែងនៅទូទាំងប្រទេសចិនដោយទី

ក្រុងនីមួយៗមានទីផ្សារលក់ដុំធំៗជាច្រើន។ ផ្សារកសិកម្មស៊ីនហ្វាឌី (Beijing's Xinfadi Agricultural Market) នាទីក្រុងប៉េកាំងគឺជាទីផ្សារលក់ដុំធំជាងគេនៅភាគខាងជើងប្រទេសចិនហើយក៏ជាប្រភព ៧០% នៃបន្លែទាំងអស់ និង ៨០% នៃផ្លែឈើទាំងអស់ដែលប្រើប្រាស់នៅក្នុងទីក្រុងប៉េកាំង។ ទីផ្សារលក់ដុំផ្លែឈើនិងបន្លែជាំងណាននៃខេត្តគ័ងចូវ (Guangzhou's Jiangnan Wholesale Fruit and Vegetable Market) គឺជាទីផ្សារលក់ដុំផលិតផលនាំចូលដ៏សំខាន់បំផុតនៅក្នុងប្រទេសចិនដែលរ៉ាប់រង៧០%នៃផ្លែឈើ និងបន្លែនាំចូលទាំងអស់ទៅក្នុងប្រទេសចិន[13]។

[13] Source: Exporting Fresh Fruit and Vegetables to China, Produce Market Association, 2016

# និតិវិធីនាំចេញស្វាយ
# មួយម្ដងមួយជំហាន

| | |
|---|---|
| ជំហានទី ១ | ការចុះបញ្ជីកសិករដាំស្វាយ និងកន្លែងវេចខ្ចប់ជាមួយ អគ្គនាយកដ្ឋានកសិកម្ម (GDA) |
| ជំហានទី ២ | វិញ្ញាបនបត្រ និងស្តង់ដារ |
| ជំហានទី ៣ | ការប្រកាសពន្ធគយ និងឯកសារគាំទ្រ |
| ជំហានទី ៤ | ការដឹកជញ្ជូនស្វាយ និងការទូទាត់ប្រាក់ |

# 3 និតិវិធីនាំចេញស្វាយម្តងមួយជំហាន

## 3.1 ការចុះបញ្ជីកសិករដាំស្វាយ និងកន្លែងវេចខ្ចប់ជាមួយអគ្គនាយកដ្ឋានកសិកម្ម (GDA)

អាជីវកម្មទាំងឡាយដែលមានបំណងនាំចេញត្រូវតែធ្វើការចុះបញ្ជីជាមួយអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(MAFF)។ អគ្គនាយកដ្ឋានកសិកម្ម (GDA) នឹងបញ្ជូនបញ្ជីកសិដ្ឋាន និងកន្លែងវេចខ្ចប់ដែលបានចុះបញ្ជីទៅកាន់អគ្គរដ្ឋបាលគយនៃប្រទេសចិន(GACC)។ មុនពេលចាប់ផ្តើមពាណិជ្ជកម្ម GACC នឹងបញ្ជូនក្រុមអធិការកិច្ចមកប្រទេសកម្ពុជាដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃក្រុមហ៊ុនមួយចំនួនដែលបានចុះបញ្ជីទៅលើការគ្រប់គ្រងការដាំដុះ ការវេចខ្ចប់ ការស្តុកទុក និងការដឹកជញ្ជូនផ្លែស្វាយ។ មានតែក្រុមហ៊ុនដែលត្រូវបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និ GACC ប៉ុណ្ណោះដែលអាចនាំចេញផ្លែស្វាយទៅកាន់ប្រទេសចិន។

## 3.2 វិញ្ញាបនបត្រ និងស្តង់ដារ

- 3.2.1 ការធ្វើអធិការកិច្ច និងចត្តាឡីស័កមុនពេលនាំចេញ
- 3.2.2 ការទទួលបានវិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ
- 3.2.3 ការគ្រប់គ្រងចម្ការ
- 3.2.4 ការត្រួតពិនិត្យកត្តាអនុលោម

### 3.2.1 ការធ្វើអធិការកិច្ច និងចត្តាឡីស័កមុនពេលនាំចេញ

មុនពេលនាំចេញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើអធិការកិច្ច និងចត្តាឡីស័កទៅលើផ្លែស្វាយវេចខ្ចប់ក្នុងអត្រា ២% នៃបរិមាណសរុប។ ប្រសិនបើមានសត្វល្អិតចង្រៃដែលមានការព្រួយបារម្ភពីប្រទេសចិនត្រូវបានរកឃើញ ទំនិញនឹងមិនត្រូវបានអនុញ្ញាតឲ្យនាំចេញទៅកាន់ប្រទេសចិនទេ។ ចំពោះផ្លែស្វាយដែលមិនត្រូវបានគេរកឃើញថាមានបញ្ហាភូតគាមអនាម័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចេញវិញ្ញាបនប័ត្រភូតគាមអនាម័យយោងតាមវិធានភូតគាមអនាម័យ និងស្តង់ដារអន្តរជាតិលេខ 12 (ISPM12) ដែលបង្ហាញអំពីសូចនាករបច្ចេកទេសដូចជា ប្រភេទការសំលាប់មេរោគដោយកំដៅ ដោយកម្រិត សីតុណ្ហភាព រយៈពេល និងចំនួនទូកុងតឺន័រ ហើយបានបញ្ជាក់នៅក្នុងការប្រកាសបន្ថែមដូចខាងក្រោម ៖

> 'ទំនិញកក់(ផ្លែស្វាយ)ដែលអនុលោមទៅតាមពិធីសារនៃតម្រូវការភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែស្វាយពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិន ហើយគ្មានសមាសភាពចង្រៃដែលស្ថិតក្នុងបញ្ជីចត្តាឡីស័កដែលជាក្តីបារម្ភរបស់ប្រទេសចិន'

លើសពីនេះទៀត ឈ្មោះ ឬលេខចុះបញ្ជីចម្ការ និងកន្លែងវេចខ្ចប់ដែលពាក់ព័ន្ធនឹងត្រូវបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍បន្ថែម។

### 3.2.2 ការទទួលបានវិញ្ញាបនប័ត្រអនាម័យ និងភូតគាមអនាម័យ

ដូចប្រទេសនាំចូលដទៃទៀតដែរ ប្រទេសចិនត្រូវការភ័ស្តុតាងដើម្បីផ្ទៀងផ្ទាត់ថាគ្មានផលិតផលណាដែលមានសត្វល្អិតចង្រៃ ហើយពួកគេត្រូវការព័ត៌មានផ្សេងទៀតអំពីផលិតផលដូចជា វិធីសំលាប់មេរោគដោយប្រើ ចំហាយទឹកក្តៅ ឬការសំលាប់មេរោគដោយប្រើទឹកក្តៅមុនពេលនាំចេញ។ អ្នកនាំចេញត្រូវតែផ្តល់ឯកសារបន្ថែមដើម្បីបញ្ជាក់អំពីបញ្ហានេះ។ ឯកសារតម្រូវមានភាពខុសគ្នាពីផលិតផលមួយទៅផលិតផលមួយផ្សេងទៀត។ ឧទាហរណ៍ សម្រាប់ផ្លែស្វាយស្រស់ ជាការចាំបាច់ក្នុងការបញ្ជាក់ថាការសម្អាតផ្លែស្វាយស្រស់ត្រូវបានអនុវត្តដូចដែលបានតម្រូវក្នុងខ្លឹមសារពិធីសារផ្លែស្វាយ។ ការសម្អាតផលិតផលមុនការនាំចេញរួមមានការសម្អាតអនាម័យ និងសម្អាតសត្វល្អិតចង្រៃក្នុងប្រទេសដែលទទួលបានផលិតផល។

ដើម្បីទទួលបានវិញ្ញាបនប័ត្រភូតគាមអនាម័យពីនាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវចំណាយពេលពី ១០ ម៉ោងទៅ ១២០ ម៉ោងទើបទទួលបានវិញ្ញាបនបត្រ។

| | |
|---|---|
| **ជំហានទី១** | **ការដាក់ពាក្យ**<br>អ្នកនាំចេញ ឬពាណិជ្ជករត្រូវដាក់ពាក្យស្នើសុំសម្រាប់ការធ្វើអធិការកិច្ចភូតគាមអនាម័យ (plant quarantine inspection) សម្រាប់ការនាំចេញទំនិញទៅនាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ពាក្យស្នើសុំត្រូវរួមបញ្ចូលឯកសារពាក់ព័ន្ធ៖<br>○ ពាក្យស្នើសុំ (ទទួលពីន.ក.អ.ភ នៃ អ.ន.ក)<br>○ វិក័យបត្រ<br>○ បញ្ជីវេចខ្ចប់<br>○ ពន្ធប៉ាតង់<br>○ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម<br>○ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម<br>○ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម |
| **ជំហានទី២** | **ការត្រួតពិនិត្យឯកសារ**<br>មន្ត្រីទទួលពាក្យនឹងពិនិត្យឯកសារតម្រូវនាំចូលភូតគាមអនាម័យ និងពិនិត្យពាក្យស្នើរសុំ និងឯកសារពាក់ព័ន្ធ។<br>○ ប្រសិនបើពាក្យស្នើរសុំ និងឯកសារពាក់ព័ន្ធទាំងអស់អនុលោមតាមច្បាប់ អ្នកនាំចេញ ឬអាជីវករត្រូវបង់ប្រាក់ហើយបន្តទៅជំហានបន្ទាប់។<br>○ ប្រសិនបើពាក្យស្នើរសុំមិនគ្រប់គ្រាន់ អ្នកត្រួតពិនិត្យនឹងផ្តល់ការណែនាំដល់អ្នកនាំចេញឱ្យទៅរកឯកសារឲ្យបានគ្រប់គ្រាន់ ឬណែនាំនូវវិធានការផ្សេងទៀតដែលចាំបាច់ ឬប្រាប់អំពីការនាំចូលនូវផលិតផលនោះត្រូវបានហាមឃាត់។ |
| **ជំហានទី៣ និងទី៤** | **ការត្រួតពិនិត្យទំនិញកក់ (ផ្លែស្វាយ)**<br>បន្ទាប់ពីទទួលបានពាក្យស្នើរសុំ ហើយប្រសិនបើឯកសារមានគ្រប់គ្រាន់ ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងចាត់តាំងមន្ត្រីអធិការកិច្ចភូតគាមអនាម័យដើម្បីចុះធ្វើអធិការកិច្ចទំនិញ និងត្រួតពិនិត្យលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ការនាំចូល។<br>○ តើទំនិញត្រូវបានអនុលោមតាមច្បាប់ដែរឬទេ?<br>○ ប្រសិនបើអនុលោម ចេញវិញ្ញាបនបត្រភូតគាមអនាម័យ<br>○ ប្រសិនបើមិនអនុលោម តើអាចចាត់វិធានការកាត់បន្ថយហានិភ័យបានទេ? ប្រសិនបើមិនអាច បដិសេធក្នុងការចេញវិញ្ញាបនបត្រភូតគាមអនាម័យ។ ប្រសិនបើជាច អនុវត្តវិធានការកាត់បន្ថយហានិភ័យ និងធ្វើអធិការកិច្ចម្តងទៀត។ |

នីតិវិធីនេះអនុវត្តតាមគោលការណ៍ណែនាំនៃវិធានស្តង់ដារ និងភូតគាមអនាម័យអន្តរជាតិលេខ ១២ (ISPM No.12) ដើម្បីធានាថាទំនិញរុក្ខជាតិ ផលិតផល ឬទំនិញផ្សេងៗដែលបានឆ្លងកាត់នីតិវិធីនេះ គឺអនុលោមតាមច្បាប់ភូតគាមអនាម័យនៃប្រទេសដែលនាំចូល និងពិតជាអនុលោមតាមខ្លឹមសារដូចដែលបានពិពណ៌នានៅក្នុងគំរូវិញ្ញាបនប័ត្រ។



#### 3.2.3 ការគ្រប់គ្រងចម្ការ

ចម្ការដែលបានចុះបញ្ជីនាំចេញទាំងអស់ត្រូវបង្កើត និងអនុវត្តវិញ្ញាបនប័ត្រកម្ម GAP ឬប្រព័ន្ធវិញ្ញាបនប័ត្រកម្មអន្តរជាតិផ្សេងទៀតដើម្បីធានាបាននូវការតាមដានដំណើរការផលិតកម្ម។ គ្រប់គ្រងលក្ខខណ្ឌអនាម័យនៅចម្ការ យកចេញនូវផ្លែឈើរលួយក្នុងកំឡុងពេលប្រមូលផល និងអនុវត្តវិធានការណ៍ IPM ដូចជាការត្រួតពិនិត្យសត្វល្អិត ការគ្រប់គ្រងថ្នាំគីមីឬជីវសាស្ត្រ និងប្រតិបត្តិការកសិកម្ម។ សម្រាប់សត្វល្អិតចង្រៃក្នុងចត្តាឡីស័កដែលជាក្តីបារម្ភរបស់ប្រទេសចិន (ពាយនាមក្នុងឧបសម្ព័ន្ធ ១) ភាគីកម្ពុជាត្រូវតែត្រួតពិនិត្យ និងអង្កេតនៅចម្ការស្វាយក្នុងកំឡុងពេលផ្លែកំពុងលូតលាស់ និងប្រមូលផលដើម្បីធានាថាសត្វល្អិតចង្រៃក្នុងចត្តាឡីស័កដែលជាក្តីបារម្ភរបស់ប្រទេសចិនស្ថិតនៅក្រោមការគ្រប់គ្រង។ ចម្ការដែលបានចុះបញ្ជីទាំងអស់ត្រូវរក្សាកំណត់ត្រានៃការត្រួតពិនិត្យ និងគ្រប់គ្រងសមាភាពចង្រៃហើយផ្តល់វាទៅឲ្យGACC តាមការស្នើសុំ។ កំណត់ត្រាត្រួតពិនិត្យត្រូវតែរួមមាន ឈ្មោះសមាសធាតុផ្សំ កាលបរិច្ឆេទនៃការប្រើប្រាស់ និងកំហាប់នៃសារធាតុគីមីទាំងអស់ដែលត្រូវបានប្រើក្នុងរដូវដាំដុះ។

#### 3.2.4 ការពិនិត្យអនុលោមភាព

មុនពេលចាប់ផ្តើមការធ្វើពាណិជ្ជកម្ម GACCនឹងបញ្ជូនអ្នកជំនាញខាងចត្តាឡីស័ករុក្ខជាតិមកប្រទេសកម្ពុជាដើម្បីធ្វើការត្រួតពិនិត្យជាប្រព័ន្ធនូវអនុលោមភាព ត្រួតពិនិត្យ និងវាយតម្លៃការគ្រប់គ្រងការដាំដុះ ការកែច្នៃ ការរក្សាទុកនិងការដឹកជញ្ជូនផ្លែស្វាយ និងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចការនាំចេញ និងប្រព័ន្ធចត្តាឡីស័កនៅកម្ពុជា។ ការចំណាយសម្រាប់ការពិនិត្យ និងការធ្វើអធិការកិច្ចបឋមរបស់អ្នកជំនាញ GACCនៅប្រទេសកម្ពុជារួមទាំងការធ្វើដំណើរ ការស្នាក់នៅ និងការចំណាយផ្សេងទៀតនឹងត្រូវជាបន្ទុករបស់ភាគីកម្ពុជា។

### 3.3 ការប្រកាសពន្ធគយ និងឯកសារគាំទ្រ

- 3.3.1 លក្ខខណ្ឌតម្រូវសម្រាប់ការវេចខ្ចប់ និងចត្តាឡីស័ក
- 3.3.2 នីតិវិធីគយ/ការទទួលបានអាជ្ញាប័ណ្ណនាំចេញ
- 3.3.3 វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម

#### 3.3.1 លក្ខខណ្ឌតម្រូវសម្រាប់ការវេចខ្ចប់ និងចត្តាឡីស័ក

រាល់រុក្ខជាតិដែលវេចខ្ចប់ និងឃ្លាំងត្រូវតែបង្កើតប្រព័ន្ធតាមដានដើម្បីធានាថាផ្លែឈើនាំចេញអាចត្រូវបានតាមដានត្រឡប់ទៅចម្ការដែលបានចុះបញ្ជី។ ប្រសិនបើរុក្ខជាតិដែលវេចខ្ចប់ត្រូវបានញែកចេញពីកន្លែងសំលាប់មេរោគដោយកំដៅវាអាចត្រូវបានគេតាមដានត្រឡប់ទៅប្រភពចម្ការតាមរយៈកន្លែងសំលាប់មេរោគដែលពាក់ព័ន្ធ។ ការវេចខ្ចប់ និងសំលាប់មេរោគលើផ្លែស្វាយបន្ទាប់ពីការប្រមូលផលត្រូវធ្វើឡើងក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងរបស់ភាគីកម្ពុជា ហើយត្រូវឆ្លងកាត់ការជ្រើសរើស លាង សម្ងួត និងដំណើរការផ្សេងៗទៀតដោយដៃដើម្បីធានាថាផ្លែឈើគ្មានប្រឡាក់ដី ពីងពាងតូចៗ ខ្យង ក្រាផ្លែរលួយ និងសំណល់រុក្ខជាតិ។ ប្រសិនបើថ្នាំផ្សិតត្រូវបានប្រើប្រាស់ ពួកវាត្រូវស្របតាមស្តង់ដារសុវត្ថិភាពចំណីអាហារ

ជាតិរបស់ប្រទេសចិន។ ផ្លែស្វាយសម្រាប់នាំចេញទៅប្រទេសចិនត្រូវតែសម្លាប់មេរោគដោយកម្តៅ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងរាលដាលរបស់សត្វរុយចោះផ្លែរស់។

### 3.3.2 នីតិវិធីគយ/ការទទួលបានអាជ្ញាប័ណ្ណនាំចេញ

អ្នកនាំចេញថ្មីត្រូវតែចុះឈ្មោះចូលប្រព័ន្ធ ASYCUDA នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករមុនពេលដែលអាជ្ញាធរគយទទួលស្គាល់ការនាំចេញដោយស្វ័យប្រវត្តិ។ បន្ទាប់ពីទទួលបានវិញ្ញាបនប័ត្រភូតគាមអនាម័យ អ្នកនាំចេញត្រូវមានលិខិតអនុញ្ញាតិពីនាយកដ្ឋានគ្រប់គ្រងនាំចេញ GDCE ឬនៅច្រកចេញ។ ឯកសារសំខាន់ៗសម្រាប់ការអនុញ្ញាតនេះរួមមានៈ (ដំណើរការជាក់លាក់ត្រូវបានពិពណ៌នានៅក្នុងឧបសម្ព័ន្ធទី២)។

| សម្រាប់រាល់ការដឹកជញ្ជូន | សម្រាប់ការដឹកជញ្ជូនតែម្តង |
|---|---|
| ▪ វិក្កយបត្រ និងបញ្ជីវេចខ្ចប់<br>▪ លិខិតស្នើសុំសម្រាប់ធ្វើអធិការកិច្ចទំនិញ (ក្នុងរោងចក្រតែប៉ុណ្ណោះ)<br>▪ លិខិតអនុញ្ញាតឱ្យដើងសាគយ | ▪ លិខិតចុះបញ្ជីក្រុមហ៊ុនពីក្រសួងពាណិជ្ជកម្ម<br>▪ ពន្ធប៉ាតង់<br>▪ វិញ្ញាបនបត្រចុះបញ្ជីពន្ធ (អាករ) |

(ឧទាហរណ៍នៃឯកសារភ្ជាប់មាននៅក្នុងឧបសម្ព័ន្ធទី៣)

ពេលដែលផ្លែឈើមកដល់កំពង់ផែប្រទេសចិន ប្រទេសនាំចេញតម្រូវឱ្យផ្តល់របាយការណ៍វាស់ស្ទង់សីតុណ្ហភាព និងកំណត់ត្រាសីតុណ្ហភាពសំលាប់មេរោគដល់មន្ត្រី GACC ដើម្បីធ្វើសវនកម្ម។

### 3.3.3 វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម

លិខិតបញ្ជាក់ប្រភពដើម (Certificate of Origin) គឺជាឯកសារដែលត្រូវបានប្រើក្នុងពាណិជ្ជកម្មអន្តរជាតិដើម្បីបញ្ជាក់ថាទំនិញដែលផលិតនៅក្នុងប្រទេសកម្ពុជាដែលជាកន្លែងវាត្រូវបាននាំចេញ។ លិខិតបញ្ជាក់ប្រភពដើមត្រូវបានបំពេញដោយអ្នកនាំចេញហើយត្រូវបានបញ្ជាក់ដោយស្ថាប័នដែលទទួលបានការទទួលស្គាល់ក្នុងករណីព្រះរាជាណាចក្រកម្ពុជាក្រសួងពាណិជ្ជកម្មជាអ្នកបញ្ជាក់ថាទំនិញនៅក្នុងការដឹកជញ្ជូននាំចេញជាក់លាក់ណាមួយត្រូវបានដាំ ផលិត ឬកែច្នៃនៅក្នុងប្រទេសជាក់លាក់ណាមួយ។ សម្រាប់លិខិតបញ្ជាក់ប្រភពដើមដែលមានសុពលភាព វាត្រូវតែចុះហត្ថលេខាដោយអ្នកនាំចេញ និងមានសហហត្ថលេខាដោយក្រសួងពាណិជ្ជកម្ម។ លិខិតបញ្ជាក់ប្រភពដើមបញ្ជាក់ថាទំនិញនៅក្នុងការដឹកជញ្ជូនណាមួយត្រូវមានប្រភពដើមជាក់លាក់ក្រោមនិយមន័យនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ឬពហុភាគីជាក់លាក់មួយ។ វិញ្ញាបនបត្រនេះត្រូវបានតម្រូវដោយអាជ្ញាធរគយរបស់ប្រទេសក្នុងការសម្រេចថាតើ ការនាំចូលគួរទទួលបានអត្ថប្រយោជន៍ពីការអនុគ្រោះស្របតាមតំបន់ពាណិជ្ជកម្មពិសេស ឬសហព័ន្ធគយដូចជា សហភាពអឺរ៉ុប អាស៊ាន ឬកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង (NAFTA) ឬមុនពេលការយកពន្ធលើទំនិញត្រូវបានអនុវត្ត។

ដើម្បីដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ប្រភពដើមសម្រាប់នាំចេញទៅប្រទេសចិនបាន អ្នកនាំចេញត្រូវការទម្រង់លិខិតបញ្ជាក់ប្រភពដើមអក្សរ(E)។ អ្នកនាំចេញត្រូវទៅនាយកដ្ឋាននាំចូលនិងនាំចេញនៃអគ្គនាយកដ្ឋាន សេវាកម្មពាណិជ្ជកម្ម។ ឯកសារចាំបាច់មាន៖

- លិខិតអនុញ្ញាតពីក្រុមហ៊ុនទៅក្រសួងពាណិជ្ជកម្ម (ឧ. ក្នុងឧបសម្ព័ន្ធ៣)
- វិក្កយបត្រលក់ បញ្ជីវេចខ្ចប់ និងកិច្ចសន្យាលក់
- របាយការណ៍ត្រួតពិនិត្យពីមន្ត្រីពាណិជ្ជកម្ម
- វិក័យបត្រដឹកទំនិញ/វិក័យបត្រដឹកជញ្ជូនតាមផ្លូវអាកាស
- ការប្រកាសពន្ធគយ

បច្ចុប្បន្ន អ្នកនាំចេញអាចដាក់ពាក្យស្នើរសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម៖ https://co.moc.gov.kh

3.4 ការដឹកជញ្ជូនផ្លែស្វាយ និងការទូទាត់ប្រាក់
- 3.4.1 ការរៀបចំផ្លែស្វាយសម្រាប់នាំចេញ
- 3.4.2 ការវេចខ្ចប់ និងបិតស្លាកសញ្ញាផ្លែស្វាយ
- 3.4.3 ការដឹកជញ្ជូនផ្លែស្វាយពីប្រទេសកម្ពុជាទៅប្រទេសចិន
- 3.4.4 ការបង្កើត និងអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនដឹកជញ្ជូននាំចេញ
- 3.4.5 ភ្នាក់ងារ និងអ្នកចែកចាយ
- 3.4.6 និតិវិធីទូទាត់ប្រាក់

### 3.4.1 ការរៀបចំផ្លែស្វាយសម្រាប់នាំចេញ

អ្នកលក់ ឬអ្នកនាំចេញត្រូវរៀបចំកាលវិភាគផ្គត់ផ្គង់ ឬផលិតកម្មឱ្យបានទាន់ពេលវេលា និងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមហ៊ុនដឹកជញ្ជូនលើកាលបរិច្ឆេទទទួលទំនិញដែលបានព្រមព្រៀងគ្នា។ ប្រសិនបើអ្នកលក់ ឬអ្នកនាំចេញបានចុះកិច្ចសន្យាជាមួយអ្នកអ្នកដាំដុះច្រើន អ្នកលក់ត្រូវកំណត់ពេលផ្គត់ផ្គង់ ឬផលិតកម្មរួមដោយផ្អែកលើបរិមាណផ្លែស្វាយដែលត្រូវដឹកជញ្ជូនម្តង។ ក្នុងករណីជាច្រើន (យោងតាមកិច្ចព្រមព្រៀង) សម្ភារៈវេចខ្ចប់សមស្របត្រូវតែអាចរកបានសម្រាប់អ្នកលក់/អ្នកនាំចេញ។ ដូច្នេះ សម្ភារៈទាំងនេះចាំបាច់ត្រូវផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលា។ នេះមានន័យថារាល់ផែនការដឹកជញ្ជូន និងការរៀបចំត្រូវតែធ្វើឱ្យច្បាស់ដោយមានយន្តការសមស្រប។

ដោយសារតែផ្លែស្វាយស្រស់ងាយខូច សម្ភារៈវេចខ្ចប់ និងកន្លែងរក្សាទុកត្រូវតែរៀបចំឲ្យបានទាន់ពេលវេលា។ នៅពេលដែលផ្លែស្វាយត្រូវបានប្រមូលផលគ្រប់គ្រាន់ និងដល់ពេលវេលានាំចេញ វានឹងត្រូវបានធ្វើប្រព្រឹត្តិកម្ម (សំលាប់មេរោគ) ដើម្បីសម្លាប់សត្វល្អិតចង្រៃតាមលក្ខខណ្ឌតម្រូវក្នុងកិច្ចព្រមព្រៀងដែលមានចែងក្នុងពិធីសារចុះហត្ថលេខា។ ការសំលាប់មេរោគដោយកំដៅមានពីរប្រភេទដូចដែលបានព្រមព្រៀងគ្នា៖

- ការសំលាប់មេរោគដោយចំហាយទឹកក្តៅ៖ ការសំលាប់មេរោគដោយចំហាយទឹកក្តៅនៅសីតុណ្ហភាពផ្លែឈើ ៤៧ អង្សារសេ រយៈពេល២០នាទីក្នុងសំណើម៩៥%។
- ការសំលាប់មេរោគដោយជ្រមុជ (ផ្លែឈើចូលក្នុងទឹកក្តៅឧណ្ហៗ) នៅសីតុណ្ហភាព៤៨អង្សាសេ ឬខ្ពស់ជាងនេះ រយៈពេល ៦០ នាទី។

ចុងក្រោយ ផ្លែស្វាយស្រស់នឹងត្រូវវេចខ្ចប់ដាក់ចូលទូកុងតឺន័រ ហើយដឹកទៅកន្លែងលក់ (ដែលអ្នកលក់ឲ្យស្វាយទៅអ្នកទិញ)។

### 3.4.2 ការវេចខ្ចប់ និងដាក់ស្លាកឈ្មោះផ្លែស្វាយ

- **ស្លាកសញ្ញា៖** តាមពិធីសារកូតតាមអនាម័យ ស្វាយគួរតែត្រូវដាក់ស្លាកឲ្យបានច្បាស់លាស់ជាមួយនឹងពាក្យ "នាំចេញទៅសាធារណរដ្ឋប្រជាមានិតចិន" ជាភាសារអង់គ្លេស និងប្រភេទពូជ ប្រភពដើម (ឧ.កម្ពុជា) ចម្ការ (កសិករ) រុក្ខជាតិវេចខ្ចប់ និងព័ត៌មានពីសហគ្រាសសម្អាតស្វាយជាភាសារអង់គ្លេស។




រូបភាពទី២៖ ឧទាហរណ៍នៃស្លាកសញ្ញានាំចេញពីប្រទេសកម្ពុជា

- **ប្រអប់វេចខ្ចប់៖** ភាគច្រើននៃការត្អូញត្អែរបស់អ្នកទិញផលិតផល និងអតិថិជនអាចត្រូវបានរកឃើញទាក់ទងនឹងការវេចខ្ចប់មិនល្អដោយសារតែការរចនាមិនត្រឹមត្រូវ ឬការជ្រើសរើស និងការប្រើប្រាស់មិនសមរម្យ។ កញ្ចប់ផលិតផលដែលបានរចនាត្រឹមត្រូវគួរតែផ្ទុក ការពារ និងកំណត់អត្តសញ្ញាណផលិតផលដែលធ្វើឲ្យមនុស្សគ្រប់គ្នាពេញចិត្តចាប់តាំងពីអ្នកដាំរហូតដល់អតិថិជន។

**<u>ការណែនាំខ្លះៗសំរាប់ការវេចខ្ចប់ "ល្អ"</u>**

**ភាពអាចប្រើប្រាស់ឡើងវិញបាន/ការរលាយតាមបែបជីវសាស្ត្រ**

ការកើនឡើងចំនួនទីផ្សារ និងទីផ្សារនាំចេញជាច្រើនបានធ្វើអោយមានការរឹតបន្តឹងការបោលសំរាមសម្រាប់ សម្ភារៈវេចខ្ចប់។ នៅពេលអនាគត ផលិតផលវេចខ្ចប់ស្ទើរតែទាំងអស់នឹងអាចកែច្នៃឡើងវិញបាន ឬអាចរលាយតាមបែបជីវសាស្ត្របាន ឬទាំងពីរ។

**ប្រភេទ**

និន្នាការគឺឆ្ពោះទៅរកការប្រើប្រាស់ការវេចខ្ចប់ដុំ (ទ្រង់ទ្រាយធំ) សម្រាប់អ្នកកែច្នៃនិងអ្នកទិញដុំ និងកញ្ចប់តូចៗសម្រាប់អ្នកប្រើប្រាស់។

**ភាពទាក់ទាញការលក់**

រូបភាពពាណិជ្ជកម្មដែលមានគុណភាពខ្ពស់កំពុងត្រូវបានប្រើដើម្បីបង្កើនការទាក់ទាញការលក់។ រូបភាពចំរុះពណ៌ ការប្រើប្រាស់អក្សរប្លែកៗ និងរូបសញ្ញាជារឿងពេញនិយម។

**រយៈពេលប្រើប្រាស់បាន**

ការវេចខ្ចប់ផលិតផលបែបទំនើបអាចត្រូវបានផលិតតាមលក្ខណៈបច្ចេកទេសសម្រាប់ទំនិញនីមួយៗដើម្បីពន្យាររយៈពេលប្រើប្រាស់ និងកាត់បន្ថយកាកសំណល់។

- **ការវេចខ្ចប់៖** ផ្លែស្វាយនីមួយៗនឹងត្រូវបានខ្ចប់ជាមួយស្រោមស្នោរ (Polystyrence) ដែលស្អាត ទន់ និងអាចពង្រីកបានដើម្បីការពារស្នាមជាំមុនពេលវេចខ្ចប់ក្នុងប្រអប់/កេះ។ សំភារៈវេចខ្ចប់ត្រូវតែអាចរក្សាផលិតផលក្នុងបរិមាណសមស្របងាយស្រួលសម្រាប់ដឹកជញ្ជូន និងចែកចាយ។ ផលិតផលវេចខ្ចប់គួរតែត្រូវនឹងផ្នែកខាងក្នុងនៃសំភារៈវេចខ្ចប់ហើយនៅសល់ចន្លោះតិចតួច។ ប្រសិនបើប្រអប់ខ្យល់ត្រូវបានប្រើ គ្រប់ពេលដែលបើកខ្យល់ចេញ ប្រអប់គួរតែត្រូវបានគ្របដោយរបាំងការពារសត្វល្អិត ហើយផ្នែកទាំងអស់នៃប្រអប់គួរតែភ្ជាប់ជាមួយក្រដាសស្អិតដើម្បីការពារសត្វល្អិតចូល។ សម្ភារៈដែលប្រើក្នុងការវេចខ្ចប់គួរតែស្អាត និងស្រស់ដើម្បីជៀសវាងការខូចខាតដល់ផ្នែកខាងក្នុង ឬខាងក្រៅនៃផលិតផល។ ការប្រើប្រាស់សម្ភារៈផ្សេងៗ ជាពិសេសក្រដាស ឬផ្លាកសញ្ញាពាណិជ្ជកម្មត្រូវបានអនុញ្ញាតសម្រាប់រូបភាពបោះពុម្ព ឬស្លាកសញ្ញាដែលធ្វើពីទឹកថ្នាំឬការបិទដែលគ្មានជាតិពុល។ ផ្លែស្វាយត្រូវបានដាក់ក្នុងកន្ត្រកដោយយោងទៅតាមក្រមភាពងាយស្រួលអន្តរជាតិសម្រាប់ការវេចខ្ចប់ និងដឹកជញ្ជូនផ្លែឈើ និងបន្លែស្រស់។




រូបភាពទី៣៖ ឧទាហរណ៍នៃប្រអប់វេចខ្ចប់ផ្សេងៗគ្នា

- **ការការពារ៖** ប្រអប់វេចខ្ចប់ត្រូវតែការពារផលិតផលពីការបំផ្លាញដោយមេកានិច និងលក្ខខណ្ឌបរិស្ថានមិនល្អក្នុងអំឡុងពេលលើកដាក់ និងចែកចាយ។ សម្រាប់អ្នកទិញផលិតផល កញ្ចប់ផលិតផលដែលរហែក ធ្លាយ ឬខូចបានបង្ហាញពីការកង្វះការយកចិត្តទុកដាក់ក្នុងការលើកដាក់។ ប្រអប់វេចខ្ចប់ផលិតផលត្រូវតែរឹងមាំគ្រប់គ្រាន់ក្នុងការទប់ទល់នឹងការខូចខាតក្នុងកំឡុងពេលវេចខ្ចប់ ស្តុកទុក និងដឹកជញ្ជូនទៅទីផ្សារ។

ដោយសារតែកញ្ចប់ផលិតផលស្ទើរតែទាំងអស់ត្រូវបានដាក់លើបន្ទះឈើ ប្រអប់វេចខ្ចប់ផលិតផលគួរតែមានភាពរឹងមាំដើម្បីទប់ទល់នឹងការសង្កត់នៅក្នុងសីតុណ្ហភាពទាប និងបរិយាកាសសំណើមខ្ពស់។ ទោះបីជាថ្លៃដើមរបស់សម្ភារៈវេចខ្ចប់កើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយក៏ ប្រអប់វេចខ្ចប់ផលិតផលដែលមានគុណភាពអន់និងមានទម្ងន់ស្រាលងាយនឹងបង្កការខូចខាតដោយសារការដឹកជញ្ជូនឬសំណើម លែងត្រូវបានប្រើប្រាស់ដោយអ្នកវេចខ្ចប់ ឬអ្នកទិញទៀតហើយ។

ផលិតផលដែលមានគោលដៅសម្រាប់ទីផ្សារនាំចេញ ទាមទារឱ្យប្រអប់វេចខ្ចប់ផលិតផលមានភាពរឹងមាំបន្ថែមទៀត។ ផលិតផលដែលត្រូវបានដឹកជញ្ជូនតាមអាកាសតម្រូវឲ្យមានការវេចខ្ចប់ ទំហំកញ្ចប់ និងអ៊ីសូឡង់ពិសេស។

ការខូចខាតដែលបណ្តាលមកពីការគ្រប់គ្រងបរិស្ថានមិនល្អក្នុងកំឡុងពេលលើកដាក់ និងការផ្ទេរផលិតផលជាមូលហេតុចំបងមួយក្នុងចំណោមហេតុសំខាន់ៗនៃការមិនទទួលយកផលិតផល និងបង្ករភាពមិនពេញចិត្តពីអ្នកទិញនិងអ្នកប្រើប្រាស់។ ប្រអប់វេចខ្ចប់ផលិតផលគួរតែសមស្របទៅនឹងផលិតផលដែលអាចបង្កើតជាបរិស្ថានល្អបំផុតសម្រាប់រក្សាអាយុកាលប្រើប្រាស់ផលិតផលបានយូរបំផុត។

- **ការកំណត់អត្តសញ្ញាណ៖** សំបកវេចខ្ចប់ត្រូវតែបង្ហាញ និងផ្តល់នូវព័ត៌មានដែលមានប្រយោជន៍អំពីផលិតផល។ ជាទូទៅ (ហើយអាចតម្រូវក្នុងករណីខ្លះ) ព័ត៌មានដែលត្រូវផ្តល់មានដូចជា ឈ្មោះផលិតផល យីហោ ទំហំ ចំណាត់ថ្នាក់ ពូជ ទម្ងន់សរុប ចំនួនឯកតា អ្នកដាំ អ្នកដឹកជញ្ជូន និងប្រទេសជាអ្នកផលិត។

លេខកូដផលិតផលសកល (UPC ឬលេខបារកូដ) អាចត្រូវបានបញ្ចូលជាផ្នែកមួយនៃការស្លាកសញ្ញា។ UPCs ដែលត្រូវបានប្រើនៅក្នុងឧស្សាហកម្មម្ហូបអាហារមានលេខកូដចំនួន ១០ ខ្ទង់ដែលអាចស្កេនបានដោយម៉ាស៊ីន។ លេខប្រាំខ្ទង់ដំបូងគឺជាលេខដែលបានកំណត់ទៅឲ្យអ្នកផលិតជាក់លាក់ណាមួយ (អ្នកវេចខ្ចប់ ឬអ្នកដឹកជញ្ជូន) ហើយលេខ ៥ ខ្ទង់បន្ទាប់តំណាងឱ្យព័ត៌មានពីផលិតផលណាមួយដូចជា ប្រភេទផលិតផល និងទំហំកញ្ចប់។ ទោះបីជាមិនមានព័ត៌មានអំពីតម្លៃក៏ដោយ ក៏UPCs ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងដោយអ្នកវេចខ្ចប់ អ្នកដឹកជញ្ជូន អ្នកទិញ និងអ្នកលក់រាយ ដោយសារវាជាវិធីសាស្រ្តមួយលឿន និងងាយស្រួលក្នុងការគ្រប់គ្រងស្តុក និងគណនេយ្យចំណាយ។ ការប្រើប្រាស់ UPCs ប្រកបដោយប្រសិទ្ធភាព ទាមទារឱ្យមានការសម្របសម្រួលជាមួយអ្នកគ្រប់គ្នាដែលធ្វើការជាមួយសំបកវេចខ្ចប់ផលិតផល។

### 3.4.3 ការដឹកជញ្ជូនផ្លែស្វាយពីប្រទេសកម្ពុជាទៅប្រទេសចិន

បច្ចុប្បន្ននេះ ផ្លូវដឹកជញ្ជូនដោយផ្ទាល់ពីប្រទេសកម្ពុជាទៅកាន់ប្រទេសចិននៅមានកំរិត។ ប្រទេសកម្ពុជាមិនមានព្រំដែនជាប់ជាមួយប្រទេសចិនទេ ហើយជាលទ្ធផលប្រទេសកម្ពុជាត្រូវពឹងផ្អែកលើកំពង់ផែទីក្រុងហូជីមិញ (HCM) ដែលជាមជ្ឈមណ្ឌលដឹកជញ្ជូនផ្លែឈើរបស់ខ្លួនទៅកាន់ប្រទេសចិន។ ប៉ុន្តែផ្លែស្វាយពីប្រទេសកម្ពុជាក៏ត្រូវបានដឹកជញ្ជូនឆ្លងកាត់ព្រំដែនពីប្រទេសវៀតណាមទៅកាន់ប្រទេសចិនដែរ (មិនស្របច្បាប់)។

ដោយសារពាណិជ្ជកម្មផ្លែស្វាយផ្លូវការកំពុងកើនឡើងជាលំដាប់ ផ្លូវនាំចេញដែលត្រូវបានប្រើសម្រាប់ការនាំចេញផ្លែចេកបានផ្តល់នូវការណែនាំមួយចំនួនសម្រាប់ការការដឹកជញ្ជូនផ្លែស្វាយទៅកាន់ប្រទេសចិន។ ផ្លូវសំខាន់ៗនៃការដឹកជញ្ជូនផ្លូវការចំនួន៤ សម្រាប់ការដឹកជញ្ជូនផ្លែស្វាយស្រស់ទៅប្រទេសចិនមានដូចជា ផ្លូវគោក ផ្លូវសមុទ្រ ផ្លូវទន្លេ និងផ្លូវអាកាស។ តម្លៃសម្រាប់ការដឹកជញ្ជូនតាមរយៈផ្លូវទាំង៤នេះមានភាពខុសគ្នាច្រើន។ ការដឹកជញ្ជូនតាមកំពង់ផែដែលមានទំនាក់ទំនងល្អ និងមានកប៉ាល់ចូលចតញឹកញាប់មានតំលៃទាប និងចំណាយពេលដឹកជញ្ជូនខ្លី។ កំពង់ផែដែលកប៉ាល់មិនសូវចូលចតជាទូទៅត្រូវចំណាយថ្លៃ និងមានលទ្ធភាពដឹកជញ្ជូនតិច។ ផ្លូវដឹកជញ្ជូនកំពុងវិវឌ្ឍយ៉ាងឆាប់រហ័ស ហើយព័ត៌មានខាងក្រោមនេះគ្រាន់តែជាការចង្អុលបង្ហាញអំពីផ្លូវ ដែលសមស្របសម្រាប់ការនាំចេញផ្លែចេកដែលក៏អាចត្រូវបានប្រើសម្រាប់ការនាំចេញស្វាយផងដែរ។

ជម្រើសដឹកជញ្ជូន និងផ្លូវចំនួនបួនមានដូចខាងក្រោម៖

- **តាមផ្លូវគោក៖** ពីច្រកព្រំដែនកម្ពុជាទៅច្រកព្រំដែនវៀតណាម៖ **ក)** ពីបាវិតនៅកម្ពុជាទៅម៉ុកបាយ (Moc Bai) វៀតណាម **ខ)** ពីត្រពាំងផ្លុងនៅកម្ពុជាទៅហ្សាមាត (Xa Mat) នៅវៀតណាម **គ)** ពីត្រពាំងស្រែនៅកម្ពុជាទៅ

ហាវលូ (Hoa Lu) នៅប្រទេសវៀតណាម។ ផ្លែឈើទាំងនេះនឹងដឹកជញ្ជូនពីប្រទេសវៀតណាមទៅកាន់ក្រុងពីងសៀង(Pingxiang) បន្ទាប់មកទៅកាន់ទីផ្សារធំៗនៅប្រទេសចិន។ ផ្លូវតូចៗផ្សេងទៀតរួមមានៈ ពីអូយ៉ាដាវនៅកម្ពុជាទៅឡឺត្រាញ់ )Le Tranh( នៅវៀតណាមហើយបន្ទាប់មកឆ្ពោះទៅកំពង់ផែនានាក្នុងប្រទេសចិន។

- **តាមទន្លេៈ** ពីភ្នំពេញទៅហូជីមិញ។ ចំពោះការផ្ទេរពីទីក្រុងហូជីមិញមានផ្លូវដឹកជញ្ជូនជាច្រើនទៅប្រទេសចិន។ បច្ចុប្បន្ន កំពង់ផែធំៗពីរនៅប្រទេសចិនដែលទទួលការនាំចូលចេក គឺកំពង់ផែសៀងហៃ (Shanghai) និងកំពង់ផែដាលៀន (Dalian)។

- **សេវាដឹកជញ្ជូនតាមសមុទ្រៈ** ពីភ្នំពេញ-ព្រះសីហនុ-ក្រុងសៀងហៃ។ បច្ចុប្បន្នផ្លូវនេះត្រូវចំណាយពេល ១៤ ថ្ងៃ ហើយវាតម្រូវឱ្យឈប់នៅកំពង់ផែមួយផ្សេងទៀតនៅតាមផ្លូវ។ ក្រុមហ៊ុនចិនមួយចំនួនកំពុងរកមធ្យោបាយដឹកជញ្ជូនដោយផ្ទាល់ពីក្រុងព្រះសីហនុទៅកាន់ក្រុងសៀងហៃដែលចំណាយពេលត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ហើយរំពឹងថានឹងបើកនៅពេលក្រោយក្នុងឆ្នាំ ២០២០ ។ មានផ្លូវដឹកជញ្ជូនតែមួយប៉ុណ្ណោះពីក្រុងព្រះសីហនុទៅសៀងហៃ។ បច្ចុប្បន្ន មានតែក្រុមហ៊ុនមួយទេដែលកំពុងប្រើប្រាស់ផ្លូវនេះ។

- **សេវាដឹកជញ្ជូនតាមផ្លូវអាកាសៈ** ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទៅអាកាសយានដ្ឋានសៀងហៃ។ បច្ចុប្បន្ននេះមិនមានការដឹកជញ្ជូនតាមផ្លូវអាកាសទេ។ នៅពេលអនាគត ការនាំចេញស្វាយអាចត្រូវបានបញ្ជូនតាមអាកាសយានដ្ឋានសំខាន់ៗដែលពួកគេនឹងត្រូវបញ្ជូនទៅដូចជាក្រុងសៀងហៃ ក្រុងជាំងស៊ូ (Zhengzhou) និងក្រុងគ័ងចូវ (Guangzhou)។

កំពង់ផែធំៗនៅក្នុងប្រទេសចិនដែលទទួលបានផ្លែឈើពីទីក្រុងហូជីមិញ (ក្រៅពីក្រុងសៀងហៃ និងដាលៀន) រួមមានៈ គីនចូវ (Qinzhou) សឹកគូ (Shekou) គីនដាវ (Qingdao) និងធានជីន (Tianjin)។ ច្បាស់ណាស់ថា មានកំពង់ផែជាច្រើនទៀតដែលអាចទទួលបានផ្លែឈើដែរ ប៉ុន្តែជាទូទៅក្នុងបរិមាណតិចតួចណាស់សម្រាប់ផ្លែឈើកម្ពុជា។

### 3.4.4 ការកសាង និងអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មជាមួយក្រុមហ៊ុនដឹកជញ្ជូននាំចេញ

ការដឹកជញ្ជូននាំចេញអាចត្រូវបានគេមើលឃើញថាជា ផ្នែកមួយបន្ថែមទៀតដល់ដំណើរការដាំដំណាំស្វាយក្នុងស្រុករបស់ក្រុមហ៊ុននានាក្នុងពេលបច្ចុប្បន្ន។ ការយល់អំពីកន្លែងដែលអាជីវកម្មរបស់ក្រុមហ៊ុនឈរនៅក្នុងខ្សែច្រវ៉ាក់ ផ្គត់ផ្គង់ការនាំចេញនឹងជួយឱ្យក្រុមហ៊ុនកំណត់នូវជំណាក់កាលបន្ថែមទៀតអ្វីខ្លះ ដែលចាំបាច់ដើម្បីនាំយកផលិតផលផ្លែស្វាយរបស់ខ្លួនទៅកាន់ទីផ្សារនាំចេញ។

ដើម្បីឱ្យការដឹកជញ្ជូនមានប្រសិទ្ធិភាពនិងប្រសិទ្ធិផល ពាណិជ្ជករ /អ្នកនាំចេញត្រូវបង្កើតទំនាក់ទំនង និងធ្វើការរួមគ្នាជាមួយក្រុមហ៊ុនដឹកជញ្ជូន។ ចំណុចនេះចាំបាច់ណាស់ មិនត្រឹមតែសម្រាប់ការដឹកជញ្ជូនប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើឲ្យបានឲ្យកាន់តែឆាប់កាន់តែល្អ ។

ការជ្រើសរើសជំរើសត្រឹមត្រូវក្នុងការដឹកជញ្ជូនផ្លែស្វាយត្រូវតែជារឿងអាទិភាពបំផុតសំរាប់ក្រុមហ៊ុនរបស់អ្នក ហើយវាមានសារៈសំខាន់ណាស់ក្នុងការនាំចេញប្រកបដោយភាពជោគជ័យ។ ក្នុងការសម្រេចចិត្តនេះ កត្តាជាច្រើនដូចជាតម្លៃនិងវិធីសាស្ត្រនៃការទូទាត់គួរតែត្រូវយកមកពិចារណា។ ការមិនទទួលបានតម្លៃនាំចេញដែលអ្នកចង់បានអាចបណ្តាលឱ្យមានការខាតបង់ដោយសារការចំណាយផ្សេងៗដែលមិនព្រាងទុក។ ដូចគ្នានេះដែរ ការទារលុយពីកូនបំណុលនៅក្នុងប្រទេសចិនគឺជាកិច្ចការដ៏លំបាកមួយ ដូច្នេះការជ្រើសរើសជម្រើសទូទាត់ប្រាក់ត្រឹមត្រូវសម្រាប់អាជីវកម្មនឹងកាត់បន្ថយហានិភ័យលើការមិនបង់ប្រាក់។

**<u>បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការដឹកជញ្ជូនទំនិញ</u>**

- តើក្រុមហ៊ុនបានពិចារណាលើតម្រូវការខាងដឹកជញ្ជូនសម្រាប់ការនាំចេញហើយឬនៅ? ឧ. តើនៅកន្លែងណាដែលក្រុមហ៊ុនស្ថិតនៅ ក្នុងខ្សែច្រវ៉ាក់ផ្គត់ផ្គង់នាំចេញ ?
- តើក្រុមហ៊ុនបានស៊ើបអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលអាចរាំងស្ទះសក្តានុពលនាំចេញផ្លែស្វាយ ឧ .ដូចជាទីតាំងកន្លែងវេចខ្ចប់ និងទីតាំងកំពង់ផែហើយឬនៅ ?
- តើក្រុមហ៊ុនបានស៊ើបអំពីការប្រើប្រាស់សេវាកម្មផ្សេងៗរបស់ភ្នាក់ងារលក់ ឬអ្នកចែកចាយហើយឬនៅ ?
- តើក្រុមហ៊ុនបានស៊ើប/ជួលអ្នកដឹកជញ្ជូនទំនិញ ឬភ្នាក់ងារគយដែលមានសក្តានុពលហើយឬនៅ ?
- តើក្រុមហ៊ុនបានពិចារណាជម្រើសដឹកជញ្ជូនល្អបំផុតសម្រាប់អ្នកហើយឬនៅ ?ឧ. ផ្លូវអាកាស ឬផ្លូវសមុទ្រ?
- តើក្រុមហ៊ុនបានកំណត់តម្លៃ និងយល់ថាតើតម្លៃនេះគួររួមបញ្ចូលអ្វីខ្លះហើយឬនៅ ?
- តើក្រុមហ៊ុនមានការយល់ដឹងអំពីជម្រើសនៃការទូទាត់សម្រាប់ពាណិជ្ជកម្មអន្តរជាតិ (បណ្ណឥណទាន ការទូទាត់តាមប្រព័ន្ធអ៊ីនធឺណិត) និងការគ្រប់គ្រងពាណិជ្ជកម្មក្រៅប្រទេសហើយឬនៅ ?

### 3.4.5 ភ្នាក់ងារ និងអ្នកចែកចាយ

ក្រុមហ៊ុននាំចេញស្វាយនឹងមិនគ្រប់គ្រងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ទាំងមូលទេ ហើយពឹងផ្អែកលើភ្នាក់ងារ ឬអ្នកចែកចាយដើម្បីសម្រួលដល់សកម្មភាពនាំចេញរបស់ពួកគេ។ ភ្នាក់ងារ និងអ្នកចែកចាយមានតួនាទី និងទំនួលខុសត្រូវខុសៗគ្នា។ តួនាទីនិងទំនួលខុសត្រូវទាំងនេះក៏មានភាពខុសគ្នាអាស្រ័យលើថាតើពួកគេដំណើរការនៅក្នុងប្រទេសកម្ពុជា ឬចិន។ ការជ្រើសរើសភ្នាក់ងារ ឬអ្នកចែកចាយត្រឹមត្រូវ គឺសំខាន់ ព្រោះក្រុមហ៊ុននឹងពឹងផ្អែកលើចំណេះដឹង និងជំនាញរបស់ពួកគេនៅក្នុងទីផ្សារនៅប្រទេសចិន។

**តួនាទីរបស់ភ្នាក់ងារ និងអ្នកចែកចាយ**

- ពួកគេមិនយកភាពជាម្ចាស់លើទំនិញទេ
- ពួកគេតំណាងឱ្យអ្នកផ្គត់ផ្គង់សម្រាប់អ្នកទិញ
- ពួកគេត្រូវបានជួលដោយអ្នកនាំចេញក្នុងបរិមាណទឹកប្រាក់ដែលផ្អែកលើកម្រៃជើងសារនៃការលក់
- អ្នកនាំចេញទទួលខុសត្រូវចំពោះការចេញវិក័យប័ត្រ និងប្រមូលការទូទាត់ពីអតិថិជនរបស់ពួកគេ។

**តួនាទីរបស់អ្នកចែកចាយ**

- ពួកគេកាន់កាប់ភាពជាម្ចាស់នៃទំនិញ ហើយបន្ទាប់មកលក់ទំនិញបន្ត។
- ពួកគេបន្ថែមតម្លៃលើផលិតផលនៅពេលលក់បន្ត។
- លុយដែលរកបានដោយអ្នកចែកចាយ គឺខ្ពស់ជាងភ្នាក់ងារព្រោះអ្នកចែកចាយកាន់បញ្ជីសារពើភ័ណ្ឌ ផ្តល់ឥណទានសម្រាប់អតិថិជន និងទទួលខុសត្រូវផ្នែកទីផ្សារ។

**អ្នកដឹកជញ្ជូនបន្ត និងជើងសារគយ៖** ប្រសិនបើក្រុមហ៊ុនមានបំណងគ្រប់គ្រងការផ្គត់ផ្គង់ដោយខ្លួនឯងប៉ុន្តែក្រុមហ៊ុនខ្វះចំណេះដឹងក្នុងការយកផ្លែស្វាយទៅលក់នៅទីផ្សារអន្តរជាតិ ការប្រើជើងសារគយ ឬអ្នកដឹកជញ្ជូនទំនិញបន្ត គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដើម្បីដឹកជញ្ជូនផ្លែស្វាយ។ ស្ថាប័នទាំងនេះជាទូទៅមានជំឯកទេសក្នុងការដឹកទំនិញអន្តរជាតិ។ នៅពេលជ្រើសរើសអ្នកដឹកជញ្ជូនបន្ត ក្រុមហ៊ុនគួរតែពិចារណាទៅលើ បទពិសោធន៍របស់ពួកគេក្នុងការគ្រប់គ្រងផលិតផលដែលងាយខូច[14]។

[14] A list of logistic service providers and freight forwarders can be provided by GIZ-SRECA project upon request: https://connecting-asia.org/activities/

### 3.4.6 និតិវិធីទូទាត់ប្រាក់

មានវិធីទូទាត់ផ្សេងៗគ្នាជាច្រើនសម្រាប់ក្រុមហ៊ុនដូចជា៖

- **ការទូទាត់ដោយបង់ប្រាក់ជាមុន៖** អ្នកទិញបង់លុយមុនការដឹកជញ្ជូន (មិនសូវទូទៅសម្រាប់ពាណិជ្ជកម្មអន្តរជាតិ)
- **បណ្ណឥណទាន** (Letters of credit)៖ ធនាគាររបស់អ្នកនាំចូលចេញនូវឯកសារដែលបញ្ជាក់ថាពួកគេនឹងបង់លុយឱ្យអ្នកនាំចេញនៅពេលដែលលក្ខខណ្ឌនៃលិខិតឥណទានត្រូវបានបំពេញ។
- **ការផ្ទេរតាមទូរគមនាគមន៍** (Telegraphic Transfer)៖ ការផ្ទេរប្រាក់តាមទូរគមនាគមន៍ (TT) គឺជាវិធីសាស្រ្តអេឡិចត្រូនិចដែលការផ្ទេរប្រាក់ដែលត្រូវបានប្រើប្រាស់យ៉ាងសំខាន់សម្រាប់ប្រតិបត្តិការក្រៅប្រទេស។ ជាធម្មតា ការផ្ទេរប្រាក់តាមទូរគមនាគមន៍បានបញ្ចប់ក្នុងរយៈពេល ២ ទៅ ៤ ថ្ងៃនៃថ្ងៃធ្វើការអាស្រ័យលើប្រភពដើម និងទិសដៅនៃការផ្ទេរប្រាក់ក៏ដូចជាតម្រូវការប្តូររូបិយប័ណ្ណណាមួយ។
- **ការប្រមូលឯកសារ** (Documentary collection)៖ ប្រគល់ការគ្រប់គ្រងឯកសារពាណិជ្ជកម្មរបស់ក្រុមហ៊ុនទៅឲ្យធនាគាររបស់ក្រុមហ៊ុន។
- **លក្ខខណ្ឌឥណទាន** (Credit terms)៖ ការទូទាត់នឹងកើតឡើងបន្ទាប់ពីក្រុមហ៊ុនបានដឹកជញ្ជូនផ្លែស្វាយ។

ចំពោះការទូទាត់ថ្លៃផ្លែឈើស្រស់ ជាទូទៅវិធីសាស្រ្តទូទាត់តាមលិខិតឥណទានមិនត្រូវបានប្រើទេព្រោះវាចំណាយពេលយូរដើម្បីបំពេញការទូទាត់ ឯកសារមានភាពស្មុគស្មាញ ហើយថ្លៃចំណាយខ្ពស់។ ជាទូទៅវិធីសាស្រ្តទូទាត់ប្រាក់គឺតាមរយៈការផ្ទេរប្រាក់តាមទូរគមនាគមន៍ (Telegrphic-T/T) ដែលរាប់បញ្ចូលទាំង ១០០% T/T ជាមុន ឬ ៨០%T/T ជាមុន ២០ %នៅពេលមកដល់។ ក្រោមរបៀបយកទំនិញជាមុនហើយបង់ប្រាក់ជាក្រោយ ជាធម្មតាគឺ១០០%T/T នៅពេលមកដល់អាស្រ័យលើចំនួនផ្លែឈើដែលលក់បាន។ មានរបៀបទូទាត់ប្រាក់មួយបែបទៀតហៅថាភាពជាដៃគូ ដែលតម្រូវឲ្យមានប្រាក់កក់ខ្លះជាមុន ហើយប្រាក់ដែលនៅសល់នឹងត្រូវទូទាត់នៅពេលលក់ផ្លែឈើបាន។

# លក្ខខណ្ឌតម្រូវជាក់លាក់
# សម្រាប់ការនាំចូលទំនិញទៅក្នុងប្រទេស

| | |
|---|---|
| ជំហានទី ៤ | ច្បាប់ និងបទប្បញ្ញត្តិ |
| ជំហានទី ៥ | អធិការកិច្ច តេស្ត និងការត្រួតពិនិត្យគុណភាព |
| ជំហានទី ៦ | ការប្រកាសពន្ធគយ និងឯកសារយោង |
| ជំហានទី ៧ | ការធ្វើអធិការកិច្ចគយ និងចត្តាឡីស័ក និងនិតិវិធីនៃការធ្វើតេស្ត |

4

## 4.1 ច្បាប់ និងបទប្បញ្ញត្តិ

### 4.1.1 ទិដ្ឋភាពទូទៅនៃបទប្បញ្ញត្តិ និងច្បាប់ និងតួនាទីរបស់ GACC

### 4.1.1 ទិដ្ឋភាពទូទៅនៃបទប្បញ្ញត្តិ និងច្បាប់ និងតួនាទីរបស់ GACC

អគ្គរដ្ឋបាលគយចិន (GACC) គឺជាស្ថាប័នសំខាន់ដែលគ្រប់គ្រងគោលនយោបាយ បទប្បញ្ញត្តិ និង ការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងការនាំចូលផ្លែឈើស្រស់របស់ប្រទេស។

មុនការរៀបចំរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលចិនឡើងវិញក្នុងឆ្នាំ ២០១៨ ការត្រួតពិនិត្យចត្តាឡីស័ក និងសុវត្ថិភាពចំណីអាហារនាំចូលថ្នាក់ជាតិ គឺជាការទទួលខុសត្រូវរបស់អគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័ក (AQSIQ)។ នៅក្នុងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ការទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និងការអនុវត្តន៍ និងបុគ្គលិកដែលទាក់ទងនឹងការនាំចូលផ្លែឈើស្រស់ត្រូវបានប្រគល់ឱ្យ GACC វិញ។ ការចាត់តាំងឡើងវិញរួមមានការផ្លាស់ប្តូរផ្នែកទាំងអស់នៃការិយាល័យបសុព្យាបាល និងរុក្ខជាតិ និងចត្តាឡីស័ក (动植物检疫司) ដើម្បីក្លាយជាផ្នែកមួយនៃ GACC ។ ទន្ទឹមនឹងនេះដែរ ការិយាល័យអធិការកិច្ច និងចត្តាឡីស័ក (CIQ) ថ្នាក់មូលដ្ឋានដែលធ្លាប់គ្រប់គ្រងដោយ AQSIQ ត្រូវបានបញ្ចូលទៅក្នុងការិយាល័យគយតំបន់របស់ចិន ហើយទីបំផុតត្រួតពិនិត្យដោយ GACC ។

មុខងាររបស់ GACC ទាក់ទងនឹងផ្លែឈើស្រស់ដែលបាននាំចូលរួមមានដូចខាងក្រោម៖

| បទបញ្ញត្តិ (ថ្នាក់ជាតិ) | ការអនុវត្តន៍ (ភាគច្រើនអនុវត្តដោយមន្ត្រីគយថ្នាក់ក្រោម) |
|---|---|
| • ផ្តល់សិទ្ធិ និងដកហូតសិទ្ធិចូលទីផ្សារសម្រាប់ផលិតផលបរទេស<br>• កំណត់លក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់ផលិតផល/ប្រទេសដោយផ្អែកលើការពិនិត្យទីតាំងជាក់ស្តែង និងវាយតម្លៃហានិភ័យ<br>• ចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងនិងសន្ធិសញ្ញាអន្តររដ្ឋាភិបាលស្តីពីពិធីសារចត្តាឡីស័ក<br>• បោះពុម្ពផ្សាយបញ្ជីផ្លែឈើស្រស់ដែលបានធ្វើបច្ចុប្បន្នភាពហើយបានអនុម័តសម្រាប់ការនាំចូលទៅប្រទេសចិនក៏ដូចជាកន្លែងវេចខ្ចប់ និងចម្ការផ្លែឈើដែលបានចុះបញ្ជីហើយ។ | • ដើរតួជាភ្នាក់ងារអធិការកិច្ចគយច្រកចូលកំពង់ផែដែលអាចរឹបអូសទំនិញក្នុងករណីឯកសារមិនគ្រប់គ្រាន់ ឬមិនត្រឹមត្រូវ<br>• ប្រមូលពន្ធ និងអាករដែលពាក់ព័ន្ធរួមមានពន្ធលើតម្លៃបន្ថែម ពន្ធ និងអាករផ្សេងៗ<br>• ធ្វើអធិការកិច្ចចត្តាឡីស័កនៅកំពង់ផែ និងចំណុចចូលប្រទេសចិន និងបដិសេធការដឹកជញ្ជូនដែលមិនអនុលោមតាមច្បាប់<br>• ធានានូវស្លាកសញ្ញាផលិតផលសមស្របសម្រាប់ការនាំចូល<br>• រឹបអូសទំនិញដែលមានការសង្ស័យថារត់ពន្ធ និងការនាំចូលដែលរំលោភច្បាប់កម្មសិទ្ធបញ្ញា។ |

## ក្រាហ្វិកទី ៣៖ ទិដ្ឋភាពទូទៅនៃមុខងារចត្តាឡីស័ក និងអធិការកិច្ចរបស់ GACC




GACC គ្រប់គ្រងការិយាល័យគយថ្នាក់ស្រុកចំនួន៤២ ដែលភាគច្រើនទាក់ទងទៅនឹងផ្នែករដ្ឋបាលថ្នាក់ខេត្តរបស់ប្រទេសចិន។ ប៉ុន្តែ ខេត្តមួយចំនួនដែលមានកំពង់ផែច្រើន ឬបរិមាណពាណិជ្ជកម្មអន្តរជាតិច្រើនមានសាខាគយថ្នាក់ស្រុកច្រើន។

ការិយាល័យគយថ្នាក់ស្រុកត្រូវបានគេដាក់ឈ្មោះតាមទីក្រុងដែលមានការិយាល័យកណ្តាលស្រុកស្ថិតនៅ។ ជាធម្មតា ប្រសិនបើខេត្តមានការិយាល័យគយថ្នាក់ស្រុកតែមួយទេ នោះស្រុកត្រូវដាក់ឈ្មោះតាមទីក្រុងរបស់ខេត្ត។ ឧទាហរណ៍ ការិយាល័យគយស្រុកណាននីង (Nanning Customs District ) ដែលត្រូវបានគេដាក់ឈ្មោះថាជាទីរួមខេត្តក្វាងស៊ី (Guangxi)[15] ហើយដែលគ្របដណ្តប់ខេត្តក្វាងស៊ី (Guangxi) ទាំងមូល។ ខេត្តក្វាងទុង (Guangdong) ជាឧទាហរណ៍មួយនៃខេត្តដែលត្រូវបានបែងចែកទៅជា ការិយាល័យគយថ្នាក់ស្រុកជាច្រើនដូចជាទីក្រុងក្វាងចូវ (Guangzhou) ស្រុកហ៊ាំងពូ (Huangpu) (ផ្នែកមួយនៃក្រុងក្វាងចូវ) ទីក្រុងស៊ិនជិន (Shenzhen) និងទីក្រុងសានទូ (Shantou)។

ជារួម សាខាគយថ្នាក់ស្រុកទាំងនេះគ្រប់គ្រងការិយាល័យគយក្នុងស្រុកជាង ៥០០ កន្លែងនៅទូទាំងប្រទេសចិនដែលមានបុគ្គលិកធ្វើអធិការកិច្ចគយ និងចត្តាឡីស័កដាក់ស្លែងលើផ្លែឈើនាំចូលនៅកំពង់ផែចូលចត។ ឧទាហរណ៍ នៅខេត្តក្វាងស៊ី (Guangxi) ក្រោមការិយាល័យគយស្រុកណាននីង (Nanning) មានការិយាល័យគយតំបន់ឈ្មោះថា

---

15 Officially, Guangxi is not a province, but an autonomous region, and its formal name is the *Guangxi* Zhuang Autonomous Region (GZAR). However, it is a provincial-level administrative unit and for all practical reasons as applies to this report, its status is the same as a province. We therefore refer to it as such for the sake of simplicity.

Qinzhou Customs (ដែលគ្រប់គ្រងលើកំពង់ផែQinzhou) ក៏ដូចជា គយច្រកមិត្តភាព (Friendship Gate Customs ) ដែលគ្រប់គ្រងភាគច្រើនលើផ្លូវគោកឆ្លងកាត់រវាងស្រុកពីងសៀង(Pingxiang) និងប្រទេសវៀតណាម។

#### 4.1.2 ច្បាប់ និងបទប្បញ្ញត្តិសម្រាប់នាំចូលផ្លែឈើស្រស់

ច្បាប់ បទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងទ្វេភាគីមួយចំនួនដែលគ្រប់គ្រងដោយគោលនយោបាយរបស់GACC សម្រាប់ការនាំចូលផ្លែឈើស្រស់រួមមាន៖

- ច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការនាំចូល និងចេញសត្វ និងចត្តាឡីស័ករុក្ខជាតិ(អនុម័ត៖ ០១ មេសា ឆ្នាំ១៩៩២)
  - បទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់នៃសាធារណរដ្ឋប្រជាមានិតចិនស្តីពីការនាំចូល និងនាំចេញសត្វ និង ចត្តាឡីស័ករុក្ខជាតិ (០១ មករា ឆ្នាំ១៩៩៧)
- ច្បាប់ស្តីពីសុវត្ថិភាពចំណីអាហារនៃសាធារណរដ្ឋប្រជាមានិតចិន (កែសម្រួល៖ ១ មិថុនា ឆ្នាំ២០១៥)
  - បទប្បញ្ញត្តិស្តីពីការអនុវត្តច្បាប់អំពីសុវត្ថិភាពចំណីអាហារនៃសាធារណរដ្ឋប្រជាមានិតចិន (០១ ធ្នូ ឆ្នាំ ២០១៩)
- GACC និងអនុក្រឹត្យ AQSIQ ដូចជាវិធានការណ៍រដ្ឋបាលស្តីពីការធ្វើអធិការកិច្ច ចត្តាឡីស័ក និងការត្រួតពិនិត្យផ្លែឈើនាំចូល (អនុក្រឹត្យ AQSIQ លេខ៦៨ ០៥ មករា ឆ្នាំ២០០៥)
- កិច្ចព្រមព្រៀងទ្វេភាគី និងអនុស្សារណៈដែលត្រូវបានចុះហត្ថលេខាដោយប្រទេសចិន និងប្រទេសនាំចេញ
  - ឧ .ពិធីសារស្តីពីលក្ខខណ្ឌតម្រូវផ្នែកភូតគាមអនាម័យសម្រាប់ការនាំចេញផ្លែស្វាយស្រស់ពីប្រទេសកម្ពុជាទៅប្រទេសចិន
    - ដូចដែលបានបកស្រាយបន្ថែមនៅក្នុងសេចក្តីប្រកាសរបស់ GACC លេខ៨៦ ឆ្នាំ ២០២០ (សេចក្តីប្រកាសដែលទាក់ទងនឹងលក្ខខណ្ឌតម្រូវភូតគាមអនាម័យសម្រាប់នាំចូលផ្លែស្វាយស្រស់របស់កម្ពុជា)។

សេចក្តីជូនដំណឹងទាក់ទងនឹងគោលនយោបាយនិងច្បាប់ថ្មី ស្ថិតិគយ និងបញ្ជីឈ្មោះចម្ការនិងកន្លែងវេចខ្ចប់ដែលត្រូវបានចុះបញ្ជីជាផ្លូវការត្រូវបានបោះពុម្ពផ្សាយជាភាសាចិននៅលើគេហទំព័របសុព្យាបាល និងចត្តាឡីស័ករុក្ខជាតិរបស់ GACC (http://dzs.customs.gov.cn/)។ សេចក្តីប្រកាសពាក់ព័ន្ធមួយចំនួនទៀតក៏ត្រូវបានបោះពុម្ពផ្សាយជាភាសារអង់គ្លេសនៃគេហទំព័រ GACC (http://english.customs.gov.cn/) ប៉ុន្តែវាមិនសូវមានលក្ខណៈទូលំទូលាយបើប្រៀបធៀបទៅនឹងព័ត៌មានដែលបានបោះពុម្ពផ្សាយជាភាសាចិន។

## 4.2 ការធ្វើអធិការកិច្ច តេស្ត និងត្រួតពិនិត្យគុណភាព

### 4.2.1 បញ្ជីឯកសារដែលត្រូវការសម្រាប់ការដឹកជញ្ជូន

### 4.2.2 ឯកសារពិសេសសម្រាប់ផ្លែស្វាយពីប្រទេសកម្ពុជា

នីតិវិធីអធិការកិច្ចចត្តាឡីស័ក និងតេស្តរបស់ GACC មានគោលបំណងសំខាន់ពីរគឺៈ

- សុវត្ថិភាពភូតគាមអនាម័យ
  - ធានាថាការដឹកជញ្ជូនមិនមានសត្វល្អិតចង្រៃពាក់ព័ន្ធ ឬភ្នាក់ងារបង្ករោគផ្សេងៗដែលអាចបង្កហានិភ័យដល់ដំណាំក្នុងស្រុក។
    - សត្វល្អិតចង្រៃពាក់ព័ន្ធជាក់លាក់ត្រូវបានចុះបញ្ជីនៅក្នុងពិធីសារនៃភូតគាមអនាម័យ។ ក្នុងករណីផ្លែស្វាយ សត្វល្អិតចង្រៃចំនួន៩ ត្រូវបានចុះបញ្ជីដែលក្នុងនោះសត្វល្អិតចង្រៃដែលមានការព្រួយបារម្ភបំផុតគឺសត្វល្អិតពពួកខ្មុងអំបូរ Sternochetus ។
- សុវត្ថិភាពមនុស្ស
  - ធានាថាកំរិតកាកសំណល់លោហៈធ្ងន់ និងថ្នាំពុលកសិកម្មមិនលើសពីស្តង់ដារកំណត់ឡើយ។
    - ផ្លែឈើដែលបាននាំចូលត្រូវមានស្តង់ដារដូចគ្នាទៅនឹងផ្លែឈើដែលដាំក្នុងស្រុកដែរ។

ដូចក្នុង*ស្តង់ដារជាតិរបស់ប្រទេសចិនសម្រាប់កំរិតសំណល់អតិបរិមា (MRLs)* សម្រាប់ថ្នាំពុលកសិកម្មនៅក្នុងផលិតផលកសិកម្ម ដូចដែលបានធ្វើបច្ចុប្បន្នភាពឆ្នាំ ២០១៩ MRLs ត្រូវបានកំណត់លើដំណាំស្វាយរួមមានប្រភេទថ្នាំសម្លាប់សមាសភាពចង្រៃ ៧៥ ប្រភេទផ្សេងៗគ្នា។

ក្នុងស្ថានភាពភាគច្រើន ប្រទេសចិនបានកំណត់តែស្តង់ដារសំណល់លោហៈធ្ងន់នៅក្នុងផ្លែឈើស្រស់សម្រាប់សារជាតុសំណរ និងជាតិកាដមីញ៉ូមតែប៉ុណ្ណោះ។ ដែនកំណត់សម្រាប់ផ្លែឈើទាំងអស់គឺ 0,1 មីលីក្រាម/គ.ក្រ សម្រាប់សារជាតុសំណរ និង0,05 មីលីក្រាម /គ.ក្រ សម្រាប់កាដមីញ៉ូមនៅក្នុងផ្នែកដែលអាចបរិភោគបាននៃផ្លែឈើ។ ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ (pdf) នៃ*ស្តង់ដារសុវត្ថិភាពម្ហូបអាហារដែលពាក់ព័ន្ធ*អាចរកបានសម្រាប់ទាញយកពីក្នុងផ្នែកសេវាកសិកម្មបរទេស នៃវិបសាយក្រសួងកសិកម្មអាមេរិក (USDA)។

  - ពិនិត្យរកភ្នាក់ងារបង្ករោគ សារជាតុគីមី ឬបញ្ហាសុវត្ថិភាពចំណីអាហារដែលល្មើសនឹងបទបញ្ញត្តិសុវត្ថិភាពចំណីអាហារ ឬអាចបង្កហានិភ័យដល់អ្នកប្រើប្រាស់។

គួរកត់សម្គាល់ថា បន្ទាប់ពីផ្លែឈើនាំចូលបានទូទាត់ពន្ធគយ និងចូលដល់ប្រទេសចិន ការធ្វើតេស្តរកកម្រិត សំណល់ជាតិពុលកសិកម្ម(MRL) និងបញ្ហាសុវត្ថិភាពចំណីអាហារផ្សេងទៀតអាចត្រូវបានធ្វើឡើងដោយអាជ្ញាធររបស់រដ្ឋាភិបាលនៅចំណុចផ្សេងទៀតនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់រួមទាំងនៅកន្លែងលក់ដុំ និងលក់រាយ។

4.2

4.3

### 4.2.1 បញ្ជីឯកសារដែលត្រូវការសម្រាប់ការដឹកជញ្ជូនផ្លែឈើស្រស់ចូលមកប្រទេសចិន[16]

ឯកសារទូទៅសម្រាប់ផ្លែឈើនាំចូល

*ផ្តល់ដោយអ្នកនាំចេញ*

- *វិញ្ញាបនបត្រភូតគាមអនាម័យផ្លូវការចេញដោយប្រទេស ឬតំបន់ដើម(输出国家或地区官方植物检疫证书)*
- *វិញ្ញាបនបត្របញ្ជាក់ប្រភពដើម (CO) (产地证书)*
- *កិច្ចសន្យាលក់(贸易合同)*
- *វិក័យបត្រចូលចត(提单)*
- *បញ្ជីវេចខ្ចប់(装箱单)*
- *ឯកសារផ្សេងៗទៀតរបស់អ្នកទិញដូចដែលបានបញ្ជាក់ដោយអ្នកនាំចូល ឬភ្នាក់ងារដឹកទំនិញបន្តនៅចិន។*
    - *នៅខែសីហាឆ្នាំ ២០២០ អ្នកនាំចេញចំណីអាហារទៅកាន់ប្រទេសចិនមួយចំនួនកំពុងត្រូវបានស្នើសុំក្រៅផ្លូវការដោយការិយាល័យគយកម្រិតតំបន់ដើម្បីផ្តល់លិខិតដែលបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការគោរពតាមបទប្បញ្ញត្តិរបស់ចិន និងសេចក្តីណែនាំស្តីពីសុវត្ថិភាពចំណីអាហារដែលចេញដោយអង្គការសុខភាពពិភពលោកទាក់ទងនឹង Covid-19 ។*

*អ្នកនាំចូល*

- *លិខិតអនុញ្ញាតិនាំចូលបសុសត្វ និងចត្តាឡីស័ករុក្ខជាតិ(进境动植物检疫许可证) សម្រាប់ប្រភេទផ្លែឈើប្រភពដើម អ្នកនាំចូល និងអ្នកនាំចេញ។*
- *លិខិតតែងតាំងភ្នាក់ងារប្រកាសពន្ធគយ (代理报关委托书, ក្នុងករណីដើរតួជាភ្នាក់ងារសម្រាប់ទូទាត់ពន្ធគយ)។*

[16] Source: GACC and importer interviews

### 4.2.2 ឯកសារពិសេសសម្រាប់ផ្លែស្វាយពីប្រទេសកម្ពុជា

*អ្នកនាំចេញ*

*របាយការណ៍បញ្ជាក់ពីកម្រិតសីតុណ្ហភាពសំលាប់មេរោគ និងកំណត់ត្រាសីតុណ្ហភាពនៃការសំលាប់មេរោគ (ដូចក្នុងពិធីសារភូតគាមអនាម័យសម្រាប់ផ្លែស្វាយស្រស់)។*

## 4.3 ដំណើរការទូទាត់ចត្តាឡីស័ក និងពន្ធគយ

- សេចក្តីជូនដំណឹងអំពីទំនិញមកដល់៖ អ្នកដឹកទំនិញត្រូវជូនដំណឹងទៅអោយអ្នកទទួលទំនិញ (អ្នកនាំចូល ឬភ្នាក់ងារ) ពីការមកដល់នៃទំនិញនៅកំពង់ផែ និងចូលក្នុងកន្លែងដែលគ្រប់គ្រងដោយអាជ្ញាធរគយចិន។
- អ្នកទទួលទំនិញបញ្ជូនទៅ GACC នូវរាល់ឯកសារចាំបាច់ទាំងអស់ហើយដាក់ពាក្យសុំធ្វើអធិការកិច្ចគយ (ដែលរួមទាំងការធ្វើអធិការកិច្ចចត្តាឡីស័ក)។

ការបញ្ជូនឯកសារជាធម្មតាធ្វើឡើងតាមអេឡិចត្រូនិចហើយអាចធ្វើបាន ២៤ ម៉ោងក្នុងមួយថ្ងៃ។

- ប្រសិនបើពាក្យសុំត្រូវបានទទួលយក ការទូទាត់ពន្ធ និងពន្ធនឹងត្រូវធ្វើឡើង។

ផ្លែស្វាយរបស់កម្ពុជាមិនជាប់ពន្ធគយទេក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN-China FTA) ប៉ុន្តែនៅតែត្រូវបង់ពន្ធលើតម្លៃបន្ថែម ៩% គិតត្រឹមខែសីហាឆ្នាំ ២០២០។

- ការធ្វើអធិការកិច្ចគយ និងចត្តាឡីស័ក (មើលលម្អិតនៅផ្នែកបន្ទាប់)
- ក្នុងករណីភាគច្រើន ប្រសិនបើការធ្វើអធិការកិច្ចត្រូវបានអនុម័ត អ្នកទទួលទទួលទំនិញត្រូវដឹកទំនិញចេញភ្លាមៗ (នេះជាចំនុចដែលផ្លែឈើស្រស់ និងទំនិញស្រស់នានាខុសគ្នាពីទំនិញផ្សេងទៀតដោយសារតែលក្ខណៈធម្មជាតិដែលងាយខូចរបស់វា)។
- ការចេញលិខិតបញ្ជាក់ "វិញ្ញាបនប័ត្រចត្តាឡីស័ក និងអធិការកិច្ចទូរផ្ទុកទំនិញចូល"។ នេះគឺជាឯកសារសំខាន់មួយដែលអ្នកលក់រាយជាច្រើនត្រូវការដើម្បីបញ្ជាក់ថាផលិតផលផ្លែឈើដែលពួកគេកំពុងលក់ត្រូវបាននាំចូលដោយស្របច្បាប់។

ក្រាហ្វិកទី ៤៖ ឧទាហរណ៍នៃវិញ្ញាបនប័ត្របញ្ជាក់ពីការធ្វើអធិការកិច្ចទំនិញចូល និង ចត្តាឡីស័ក[17]


中华人民共和国出入境检验检疫
入境货物检验检疫证明

| | | | |
|---|---|---|---|
| 收货人 | 有限公司 | | |
| 发货人 | | | |
| 品 名 | | 报检数/重量 | |
| 包装种类及数量 | | 输出国家或地区 | |
| 合同号 | | 标记及号码 | |
| 提/运单号 | | | |
| 入境口岸 | | | |
| 入境日期 | | | |

证明

签字： 日期： 2019 年 月 日

备注

“វិញ្ញាបនប័ត្របញ្ជាក់ពីការធ្វើអធិការកិច្ចទំនិញនាំចូល និងចត្តាឡីស័ក” ត្រូវបានចេញដោយគយប្រចាំកំពង់ផែដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាតិដែលពាក់ព័ន្ធដើម្បីបញ្ជាក់ថាទំនិញណាមួយត្រូវបាននាំចូលតាមបណ្តាញទូទៅ ហើយបានទទួលការធ្វើអធិការកិច្ចគយ និងវាយតម្លៃការអនុលោមភាពស្របច្បាប់ចត្តាឡីស័កយោងតាមច្បាប់ដែល

[17] Source: https://www.re-code.org/article/865?categoryid=33

អនុញ្ញាតឱ្យទំនិញត្រូវបានចែកចាយ ដឹកជញ្ជូន និងដាក់លក់ក្នុងប្រទេសដោយមានឯកសារស្របច្បាប់សម្រាប់ការប្រើប្រាស់ទីផ្សារ។

## 4.4 ការធ្វើអធិការកិច្ចបត្តាឡឹស័ក និងគយ និងនិតិវិធីនៃការធ្វើតេស្ត

ការធ្វើអធិការកិច្ចនៅនឹងកន្លែងរួមមានផ្នែកទាក់ទងទាំងបទបញ្ញត្តិគយ និងនិតិវិធីចត្តាឡីស័ក។

- ការធ្វើអធិការកិច្ចលើផ្នែកគយនៅនឹងកន្លែងរួមមានការបញ្ជាក់ថាខ្លឹមសារ ទម្ងន់ និងតម្លៃនៃទំនិញដែលត្រូវគ្នានឹងការប្រកាសដែលបានធ្វើលើឯកសារដឹកជញ្ជូន។

- លេខកុងតឺន័រត្រូវតែត្រូវនឹងលេខដែលបានប្រកាសនៅលើវិញ្ញាបនប័ត្រភូតគាមអនាម័យ (សម្រាប់ការដឹកជញ្ជូន)
- គយក៏អាចធ្វើសវនកម្មដើម្បីកំណត់ថាតើតម្លៃទំនិញដែលបានប្រកាសមានលក្ខណៈសមហេតុផលនិងមិនទាបពេក។

- ចំពោះផ្នែកចត្តាឡីស័ក ការធ្វើអធិការកិច្ចនៅនឹងកន្លែងអាចអនុវត្តបន្ទាប់ពីការធ្វើតេស្ត និងការវិភាគនៅមន្ទីរពិសោធន៍។
- ការធ្វើអធិការកិច្ចនៅនឹងកន្លែង

- ពិនិត្យរថយន្តដឹកជញ្ជូន និងសម្ភារៈវេចខ្ចប់។
  - បញ្ជាក់សម្ភារៈវេចខ្ចប់ និងវិធីសាស្ត្រអនុលោមតាមពិធីសារទ្វេភាគី និងលក្ខខណ្ឌតម្រូវរបស់ GACC សម្រាប់ផ្លែស្វាយកម្ពុជាក៏ដូចជាបញ្ជាក់ថាការដឹកជញ្ជូននេះមិនមានដី មែកឈើ ស្លឹកឈើ និងវត្ថុធាតុដែលមិនតម្រូវផ្សេងទៀត។
- ការប្រមូលសំណាកសម្រាប់ការធ្វើតេស្តនៅមន្ទីរពិសោធន៍ (ចាប់ដោយចៃដន្យ)។
- ការពិនិត្យនៅនឹងកន្លែងដែលរួមបញ្ចូលការកាត់ផ្លែឈើជាបំណែកៗ ដើម្បីពិនិត្យរកពងសត្វល្អិត ដង្កូវ ឬរោគសញ្ញាបំផ្លាញពីសត្វល្អិត ក៏ដូចជាវត្តមានរបស់ផ្សិតនៅខាងក្នុងផ្លែឈើ។
  - ការយកចិត្តទុកដាក់ជាពិសេសចំពោះសមាសភាពចង្រៃដែលពាក់ព័ន្ធចំពោះផ្លែស្វាយកម្ពុជាតាមលក្ខខណ្ឌតម្រូវការផ្នែកភូតគាមអនាម័យនៃការនាំចូលផ្លែស្វាយស្រស់របស់កម្ពុជា និងប្រព័ន្ធតាមដានការរាតត្បាតថ្នាក់កណ្តាលរបស់ GACC។
- ការប្រមូលឯកសាររូបថត ឬវីដេអូអំពីអតិសុខុមប្រាណដែលអាចបង្កគ្រោះថ្នាក់ ឬបញ្ហាផ្សេងទៀតដែលបានរកឃើញនៅក្នុងពេលធ្វើអធិការកិច្ច។
- ប្រសិនបើបញ្ហាត្រូវបានរកឃើញ សំណាកតំណាងនឹងត្រូវបញ្ជូនដាច់ដោយឡែកទៅមន្ទីរពិសោធន៍ដើម្បីវិភាគអំពីសុវត្ថិភាព និងសុខភាព និងធ្វើចត្តាឡីស័ក និងការកំណត់អត្តសញ្ញាណកត្តាចង្រៃ។

- ការធ្វើតេស្តនៅមន្ទីរពិសោធន៍ដើម្បីរកមើលកត្តាចង្រៃ និងការបំពានច្បាប់សុវត្ថិភាពចំណីអាហារ (សំណល់លោហៈធាតុធ្ងន់ និងថ្នាំពុលកសិកម្ម)។

- ការធ្វើតេស្តត្រូវបានកំណត់ដោយប្រព័ន្ធកុំព្យូទ័រស្វ័យប្រវត្តិ ហើយត្រូវចាប់ដោយចៃដន្យ។
- អ្នកនាំចូលមិនត្រូវបានជូនដំណឹងអំពីថាតើការធ្វើតេស្តផលិតផលរបស់ពួកគេត្រូវបានធ្វើឡើងដរាបណាតែមានបញ្ហាត្រូវបានរកឃើញ។

- ផ្លែឈើដែលធ្លាក់ក្នុងការធ្វើអធិការកិច្ចដោយសារតែវត្តមាននៃភ្នាក់ងារបង្ករោគដែលមានគ្រោះថ្នាក់អាចត្រូវបានសំលាប់មេរោគនៅប្រទេសចិនក្រោមការត្រួតពិនិត្យពីGACC។ ប្រសិនបើការសំលាប់មេរោគទទួលបានជោគជ័យ ផ្លែឈើអាចបញ្ចេញពីកន្លែងគយ និងយកទៅលក់។ បើមិនដូច្នោះទេ ទំនិញនឹងត្រូវបញ្ជូនត្រឡប់ទៅវិញ (ដែលអាចរួមទាំងបង្វែរគោលដៅទៅប្រទេសផ្សេង) ឬក៏បំផ្លាញចោល។

- ក្នុងករណីពិសេសផ្លែស្វាយ ជាទូទៅមិនមានវិធីសាស្ត្រសំលាប់មេរោគដែលមានប្រសិទ្ធភាពនោះទេ ដូច្នេះទំនិញនឹងត្រូវបញ្ជូនត្រឡប់មកវិញ ឬបំផ្លាញចោលប្រសិនបើធ្លាក់នៅដំណាក់កាលធ្វើអធិការកិច្ច។

- នៅតាមកំពង់ផែដែលមានបរិមាណការនាំចូលផ្លែឈើស្រស់ច្រើន ការទំនិញផ្លែឈើដែលត្រូវបានគេចាត់ទុកថាមានហានិភ័យភូតគាមអនាម័យឬបញ្ហាសុខភាពទាប នឹងត្រូវបានបញ្ចេញឱ្យទៅអ្នកទទួលទំនិញនៅពេលបញ្ចប់ការធ្វើអធិការកិច្ចនៅនឹងកន្លែង ហើយនៅតែរង់ចាំលទ្ធផលនៃការធ្វើតេស្តមន្ទីរពិសោធន៍ និងការចេញវិញ្ញាបនប័ត្របញ្ជាក់ចត្តាឡីស័ក និងអធិការកិច្ចការនាំចូលទំនិញ។
- ផ្លែឈើដែលផ្ទុកក្នុងការដឹកជញ្ជូនត្រូវតែមានប្រភពចេញពីចម្ការផ្លែឈើ កន្លែងវេចខ្ចប់ និងកន្លែងសំលាប់សត្វល្អិតចង្រៃដែលបានចុះបញ្ជីត្រឹមត្រូវជាមួយGACC ។
- អ្នកនាំចេញមិនត្រូវលាយចូលទៅក្នុងកុងតឺន័រ/ទូរដឹកជញ្ជូននូវផ្លែឈើដែលមិនបានចុះបញ្ជីក្នុងបញ្ជីវេចខ្ចប់ និងអាជ្ញាប័ណ្ណនាំចូល(ដូចជាផ្លែឈើសម្រាប់លក់ផ្សេង និងផ្លែឈើធ្វើសំណាកផ្សេង)។ ការធ្វើដូច្នេះអាចនាំឱ្យមានការមិនទទួលយកទំនិញទាំងមូល។
- បរិមាណដែលនាំចូលមិនត្រូវលើសពីបរិមាណដែលបានចុះបញ្ជីក្នុងអាជ្ញាប័ណ្ណនាំចូលឡើយ។
- ដូចដែលបានបញ្ជាក់នៅក្នុងពិធីសារភូតគាមអនាម័យ ផ្លែស្វាយកម្ពុជាដែលបាននាំចូលទៅប្រទេសចិនត្រូវតែ "គ្មានដី សត្វល្អិត ពីងពាងតូចៗ ខ្យង ផ្លែឈើរលួយ និងសំណល់ដើមនិងមែក។"
- ក្តារឈើកំណល់ដែលត្រូវបានប្រើក្នុងការដឹកជញ្ជូនត្រូវអនុវត្តតាមស្តង់ដារអន្តរជាតិសម្រាប់វិធានការផ្នែកភូតគាមអនាម័យលេខ ១៥ (ISPM-15) និងត្រូវបានដាក់ផ្លាកសម្គាល់យ៉ាងត្រឹមត្រូវ។
- ការដឹកជញ្ជូនផ្លែឈើលើកដំបូងទៅកាន់ប្រទេសចិនពីប្រទេស/តំបន់មួយទំនងជាត្រូវបានធ្វើអធិការកិច្ចយ៉ាងតឹងរឹងជាងការដឹកជញ្ជូនជាបន្តបន្ទាប់ ហើយអាចចំណាយពេលច្រើនថ្ងៃ ឬដល់មួយសប្តាហ៍ ឬច្រើនជាងនេះដើម្បីបញ្ចេញ។

- កម្មវិធីធ្វើអធិការកិច្ច និងចត្តាឡីស័កសម្រាប់ការដឹកជញ្ជូនផ្លែឈើអាចជះឥទ្ធិពលពីស្ថានភាពជាក់ស្តែងនៅចម្ការផ្លែឈើរបស់ប្រទេសនាំចេញ ដែលរួមមាន ទិន្នន័យអំពីការឆ្លងសត្វល្អិតចង្រៃដែលប្រមូលបានពីកំណត់ត្រាត្រួតពិនិត្យ និងគ្រប់គ្រងសត្វល្អិតនៅចម្ការដែលបានចែងនៅក្នុងពិធីសារនាំចេញ។
- លទ្ធផលនៃការធ្វើអធិការកិច្ច និងតេស្តចត្តាឡីស័ក និង សុវត្ថិភាពចំណីអាហារពីការិយាល័យគយតំបន់ត្រូវបានបញ្ជូនទៅទីស្នាក់ការកណ្តាល GACC ក្នុងទីក្រុងប៉េកាំង ដើម្បីប្រើប្រាស់ក្នុងប្រព័ន្ធរាយការណ៍ពីការរីករាលដាល និងប្រព័ន្ធត្រួតពិនិត្យហានិភ័យសុវត្ថិភាពចំណីអាហារ។ ប្រព័ន្ធទាំងនេះត្រូវបានប្រើដើម្បីជូនដំណឹងដល់កម្មវិធីអធិការកិច្ច និងតេស្តសម្រាប់ប្រភេទផ្លែឈើជាក់លាក់ណាមួយដែលនាំចូលពីប្រទេស/តំបន់ជាក់លាក់មួយ។ ដូច្នេះ ការធ្វើអធិការកិច្ចកន្លងទៅ ឬការធ្លាក់តេស្តសម្រាប់ផលិតផលជាក់លាក់មួយអាចជះឥទ្ធិពលដល់អត្រានៃការធ្វើអធិការកិច្ច និងការធ្វើតេស្តនាពេលអនាគតសូម្បីតែនៅកំពង់ផែចូលចតផ្សេងទៀត។

# 5 ការណែនាំសម្រាប់ផលិតកម្ម និងទីផ្សារស្វាយ [18]

## 5.1 ផលិតកម្មស្វាយ

**ធានាការផលិតគ្រប់គ្រាន់៖** មួយក្នុងចំណោមគោលការណ៍គ្រឹះនៃការត្រៀមខ្លួនសម្រាប់ការនាំចេញ គឺការដឹងថាសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការនាំចេញគឺផ្អែកទៅលើភាពអាចរកបាននៃផលិតផលរបស់ខ្លួន។ ប្រសិនបើក្រុមហ៊ុនមិនមានទិន្នផលខ្ពស់ជាងតំរូវការរបស់អ្នកទិញក្នុងស្រុកទេនោះ វាប្រហែលជាមិនមែនជាការគិតគូរដ៏ត្រឹមត្រូវក្នុងការស្វែងរកការបញ្ជាទិញពីបរទេសនោះទេ។

**ចំនួននៃការបញ្ជាទិញជាក់លាក់៖** ជាការចាំបាច់ណាស់ក្នុងការយល់ដឹងថាក្នុងករណីភាគច្រើន អ្នកទិញជនជាតិចិនមានបរិមាណបញ្ជាទិញច្បាស់លាស់ដែលពួកគេត្រូវបំពេញ។ ពួកគេក៏ទំនងជាមានតម្រូវការតាមរដូវកាលដែលអាចខុសគ្នាពីរដូវកាលផលិតកម្មនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន។ មុនពេលចាប់ផ្តើមធ្វើអាជីវកម្មជាមួយអ្នកទិញ ជាការចាំបាច់ណាស់ដែលក្រុមហ៊ុនត្រូវកំណត់នូវតម្រូវការបញ្ជាទិញអប្បបរមា និងអតិបរមាក៏ដូចជាពេលវេលានៃការបញ្ជាទិញ។ ដើម្បីរក្សាបាននូវទំនាក់ទំនងជោគជ័យយូរអង្វែងជាមួយអតិថិជនចិន ក្រុមហ៊ុនត្រូវតែអាចបំពេញបានតាមការបញ្ជាទិញ។ វិធីសាស្ត្រផលិតកម្មផ្លែស្វាយក៏អាចប្រែប្រួលផងដែរតាមតម្រូវការរបស់ប្រទេសចិនដែលជាប្រទេសនាំចូល។ ចំណុចទាំងនេះចាំបាច់ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដោយយកចិត្តទុកដាក់ជាមួយអ្នកទិញចិន។

[18] Sources: AusVeg, Horticulture Australia, 2019, Guide to the export readiness checklist

**បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការផលិតកម្មស្វាយ៖**

⇒ តើក្រុមហ៊ុនអាចផលិតទិន្នផលច្រើនគ្រប់គ្រាន់សម្រាប់បម្រើដល់ទីផ្សារគោលដៅនៅចិនបានទេ ?

⇒ តើក្រុមហ៊ុនមានធនធានក្នុងការផ្លាស់ប្តូរវិធីសាស្ត្រផលិតកម្មស្របតាមតម្រូវការសន្តិសុខជីវសាស្ត្រនៃទីផ្សារចិនដែរឬទេ ?

⇒ តើផលិតផលស្វាយបំពេញតាមបទបញ្ញត្តិ និងស្តង់ដារសុវត្ថិភាពរបស់រដ្ឋាភិបាលសម្រាប់ទីផ្សារនៅប្រទេសចិនដែរឬទេ ?

⇒ តើក្រុមហ៊ុនអាចបង្កើនផលិតកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការបានដែរឬទេ ? បើដូច្នេះ តើក្រុមហ៊ុនមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ដើម្បីធ្វើការបង្កើនផលិតកម្មដែរឬទេ ?

## 5.2 ការផ្តោតលើគុណភាព [19]

ជាការយល់ស្របទូទៅរបស់អ្នកជំនាញទាំងឡាយដែលធ្វើការក្នុងវិស័យនាំចេញនេះ គុណភាពផលិតផលគឺជាកត្តាសំខាន់បំផុតតែមួយក្នុងការកំណត់ភាពជោគជ័យសម្រាប់ការលក់ផ្លែឈើស្រស់នៅប្រទេសចិន។ ការកំណត់ភាពរាំងស្ទះក្នុងការផលិតផលិតផលដែលមានគុណភាពគួរតែស្ថិតក្នុងចំណោមចំនុចអាទិភាពចម្បងៗរបស់អ្នកដាំផ្លែឈើ និងអ្នកនាំចេញដែលចង់មានវត្តមាននៅក្នុងទីផ្សារប្រទេសចិន។ បន្ថែមលើការបង្កើនបច្ចេកទេសដាំដុះ ការប្រមូលផលនិងការគ្រប់គ្រងដី ការធានាបាននូវការគ្រប់គ្រងក្រោយប្រមូលផលនិងសេវាកម្មដឹកជញ្ជូនសមស្របក៏ជាលក្ខខណ្ឌកំណត់ដ៏សំខាន់ដែលធ្វើឲ្យផ្លែឈើទៅដល់ទីផ្សារលក់ដុំ និងអ្នកប្រើប្រាស់នៅប្រទេសចិន។ លើសពីនេះទៀត អ្នកដាំដុះ និងអ្នកនាំចេញគួរតែផ្តោតលើការស្វែងយល់អំពីចំណង់ចំណូលចិត្តរបស់ចិនចំពោះទំហំផ្លែឈើ រសជាតិ ពណ៌ និងរូបរាង ហើយពិចារណាលើការអភិវឌ្ឍន៍ផលិតផលដែលត្រូវនឹងតម្រូវការរបស់ពួកគេ។

## 5.3 ការស្រាវជ្រាវទីផ្សារ

ទីផ្សារអ្នកប្រើប្រាស់នៅប្រទេសចិនមានសក្តានុពល និងវិវឌ្ឍយ៉ាងឆាប់រហ័ស។ អ្នកផ្គត់ផ្គង់ផ្លែឈើស្រស់គួរតែពិចារណាធ្វើការស្រាវជ្រាវអំពីទីផ្សារដោយខ្លួនឯងដើម្បីយល់កាន់តែច្បាស់អំពីស្ថានភាពទីផ្សារ និងដើម្បីបង្កើតយុទ្ធសាស្ត្រផ្អែកលើភស្តុតាងសម្រាប់ផលិតផលណាមួយរបស់ពួកគេ។ ការស្រាវជ្រាវបែបនេះគួរតែរួមបញ្ចូលការវិភាគយ៉ាងលម្អិតលើការប្រកួតប្រជែងផលិតផល និន្នាការតម្លៃ និងផ្តល់ជូននូវអនុសាសន៍ដែលអាចអនុវត្តបាន។ គេគួរតែគិតគូរផងដែរនូវការប្រែប្រួលខ្លាំងនៃទីផ្សារក្នុងតំបន់របស់ប្រទេសចិន និងការប្រែប្រួលចំណង់ចំណូលចិត្ត និងទម្លាប់នៃការបរិភោគរបស់ពួកគេ។ នៅក្នុងបរិយាកាសប្រកបដោយភាពបត់បែនដូចប្រទេសចិន ព័ត៌មានទីផ្សារទាំងអស់ខាងលើមានអាយុកាលខ្លី(ដោយសារភាពប្រែប្រួលឥតឈប់ឈរ) ហេតុដូច្នេះគេគួរតែរួមបញ្ចូលយុទ្ធសាស្ត្រផ្សេងទៀតដើម្បីរក្សាបច្ចុប្បន្នភាពជាមួយនិន្នាការទីផ្សារនេះ។ របាយការណ៍ដ៏មានប្រយោជន៍មួយត្រូវបានបោះពុម្ពនៅក្នុង *"សៀវភៅណែនាំសម្រាប់អ្នកនាំចេញ*

[19] Tropical Fresh Fruit Exporter's Guide to China, March 2020, Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, Support of Regional Economic Cooperation in Asia (SRECA), Cambodia

*ផ្លែឈើតំបន់ត្រូពិកស្រស់ទៅកាន់ប្រទេសចិន"*[20]។ របាយការណ៍នេះបង្ហាញពីពាណិជ្ជកម្មរវាងចិន និងប្រទេសសមាជិកអាស៊ានចំនួន ៣ រួមមាន៖ កម្ពុជា ឡាវ និងវៀតណាមសម្រាប់ផ្លែឈើដូចខាងក្រោម៖ ស្វាយ ចេក ឪឡឹក មៀនប៉ៃលិន មៀន ផ្លែស្រកានាគ ទុរេន និងផ្លែខ្នុរ។

## 5.4 ភាពជាដៃគូក្នុងស្រុក

អ្នកនាំចេញផ្លែឈើស្រស់មានគុណភាពខ្ពស់ ត្រូវផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការជ្រើសរើសដៃគូនាំចូល និងផ្សព្វផ្សាយដែលអាចជួយពួកគេឱ្យសម្រេចសក្តានុពលរបស់ពួកគេនៅក្នុងប្រទេសចិន។ ការរក្សាគុណភាពផលិតផលពីអ្នកដាំរហូតដល់អ្នកប្រើប្រាស់ គឺជាការខិតខំរួមគ្នាដែលទាមទារឲ្យមានការគ្រប់គ្រងប្រកបដោយការយកចិត្តទុកដាក់លើការគ្រប់គ្រងខ្សែច្រវ៉ាក់ផ្គត់ផ្គង់ទាំងមូល។ ការធានានូវផលិតផលដែលមានគុណភាពខ្ពស់គួរតែត្រូវទទួលបាននូវការយកចិត្តទុកដាក់ខាងផ្នែកផ្សព្វផ្សាយទាំងនៅតាមបណ្តាញអ៊ីនធឺណិត និងលំហរព័ត៌មានផ្សេងទៀត ហើយវាក៏ទាមទាដៃគូដែលមានបណ្តាញក្នុងស្រុករឹងមាំផងដែរ។ អ្នកដាំដុះ និងអ្នកនាំចេញផ្លែឈើស្រស់មានគុណភាពខ្ពស់គួរតែស្វះស្វែងរកឱកាសដើម្បីជួប និងបង្កើតទំនាក់ទំនងនៅក្នុងប្រទេសចិន (មិនត្រឹមតែអ្នកនាំចូលប៉ុណ្ណោះទេ ប៉ុន្តែជាមួយអ្នកគ្រប់គ្រងការបញ្ជាទិញរបស់ក្រុមហ៊ុនលក់រាយធំៗ ក៏ដូចជាគេហទំព័រពាណិជ្ជកម្មតាមអ៊ីនធឺណេតផងដែរ)។

## 5.5 ការធ្វើទីផ្សារ និងការកសាងម៉ាកយីហោ

នៅក្នុងទីផ្សារផ្លែឈើដែលមានការប្រកួតប្រជែងខ្ពស់របស់ប្រទេសចិន ការកសាងម៉ាកយីហោបានក្លាយជាវិធីសាស្ត្រដ៏សំខាន់សម្រាប់អ្នកផ្គត់ផ្គង់ដើម្បីញែកផលិតផលរបស់ពួកគេ(ឲ្យខុសពីដៃគូរប្រកួតប្រជែង) ទទួលបានតម្លៃខ្ពស់ និងទទួលបានបរិមាណលក់កាន់តែច្រើន។ ការធ្វើទីផ្សារម៉ាកយីហោផ្លែឈើដែលមានប្រសិទ្ធិភាពតម្រូវឱ្យធ្វើការដោយផ្ទាល់ជាមួយដៃគូលក់រាយចិន ក៏ដូចជាការធ្វើយុទ្ធនាការទំនាក់ទំនងសាធារណៈនៅក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសចិន និងនៅលើបណ្តាញផ្សព្វផ្សាយសង្គម។ បន្ថែមលើម៉ាកយីហោសម្រាប់ក្រុមហ៊ុនផ្លែឈើនិងផលិតផលណាមួយ (ដូចដែលបានបង្ហាញដោយការផ្សព្វផ្សាយផ្លែឈើដែលដឹកនាំដោយ រដ្ឋាភិបាលនៅលើវេទិកាបណ្តាញអេឡិចត្រូនិកឈានមុខគេ និងបណ្តាញលក់រាយធំៗ) ការធ្វើកសាងម៉ាកយីហោប្រចាំប្រទេសនិងឧស្សាហកម្មក៏ទទួលបានជោគជ័យខ្ពស់ផងដែរនៅក្នុងប្រទេសចិន។

## 5.6 ការធ្វើទីផ្សារ

<u>**ស្គាល់អំពីទីផ្សាររបស់អ្នក៖**</u> ការទាក់ទាញចំណាប់អារម្មណ៍លើកដំបូងរបស់អ្នកទិញផ្លែឈើស្រស់ដែលមានសក្តានុពលគឺសំខាន់ណាស់ដើម្បីឲ្យការនាំចេញដែលទទួលបានជោគជ័យ។ សារៈសំខាន់នោះគឺ ថាត្រូវមានទំនុកចិត្ត ការឆ្លើយតបល្អ

---
[20] Tropical Fresh Fruit Exporter's Guide to China" SRECA's website
https://connecting-asia.org/wp-content/uploads/2020/03/20200410_Tropical-Fresh-Fruit-Exporter%E2%80%99s-Guide-to-China_SRECA_e-version.pdf

ភាពរួសរាយរាក់ទាក់ និងវិជ្ជាជីវៈ។ ដើម្បីឲ្យមានការទាក់ទាញចំណាប់អារម្មណ៍ល្អ ជាសំខាន់យើងត្រូវយល់ដឹងអំពីកត្តាវប្បធម៌នានាដែលអាចជះឥទ្ធិពលដល់សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការនាំចេញទៅកាន់ទីផ្សារនៅប្រទេសចិន។

**សម្ភារៈផ្សព្វផ្សាយ៖** គេហទំព័រ និងខិត្តប័ណ្ណផ្សព្វផ្សាយល្អ គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងទំនាក់ទំនងជាមួយអ្នកទិញបន្លែអន្តរជាតិ។ គេហទំព័ររបស់ក្រុមហ៊ុនគួរតែរចនាឲ្យបានស្អាត និងងាយស្រួលប្រើប្រាស់ ហើយមានមាតិកាថ្មីៗជានិច្ច។ គេហទំព័រគួរមានភាសាអង់គ្លេស ចិន និងខ្មែរ។ កាតអាជីវកម្ម (business card) ក៏ផ្តល់ភាពងាយស្រួលសម្រាប់ក្រុមហ៊ុនក្នុងការបង្កើតទំនាក់ទំនងជាមួយអ្នកទិញបន្លែដែលអ្នកជួបដោយផ្ទាល់។

**ការបកប្រែ៖** អ្នកទិញផ្លែស្វាយចិននឹងមិនអាចនិយាយ ឬអានភាសាខ្មែរ ឬអង់គ្លេសបានទេ។ ក្រុមហ៊ុនគួរគិតគូអំពីការបកប្រែលើរាល់សម្ភារៈទំនាក់ទំនងទាំងអស់ទៅជាភាសាអង់គ្លេស និងចិន និងជួលសេវាកម្មអ្នកបកប្រែសម្រាប់ការប្រជុំ។

**ទស្សនកិច្ចទៅកាន់ប្រទេសចិន (ទស្សនកិច្ចទីផ្សារ)៖** អ្នកនាំចេញផ្លែឈើស្រស់កម្ពុជាគួរតែទៅលេងប្រទេសចិនដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីទីផ្សារគោលដៅរបស់ពួកគេ និងបណ្តាញចែកចាយដែលផលិតផលរបស់ពួកគេចែកចាយទៅ។ ការធ្វើទស្សនកិច្ចទៅកាន់ប្រទេសចិនក៏ចាំបាច់សម្រាប់បង្កើតទំនាក់ទំនងជាមួយដៃគូនាំចូល និងផ្សព្វផ្សាយដែលមានសក្តានុពលផងដែរ។ ការចូលរួមពិព័រណ៍ពាណិជ្ជកម្មផ្លែឈើស្រស់ សន្និសីទ ឬចូលរួមបេសកកម្មពាណិជ្ជកម្ម គឺជាមធ្យោបាយលឿន និងងាយស្រួលបំផុតដើម្បីចាប់ផ្តើមភ្ជាប់ទំនាក់ទំនងជាមួយដៃគូដែលមានសក្តានុពលនៅពេលដែលការសិក្សាអំពីទីផ្សារដោយផ្ទាល់ជាមួយការណែនាំពីអ្នកជំនាញ។ ការជួបគ្នាដោយផ្ទាល់ក៏ជាផ្នែកមួយដ៏សំខាន់នៃវប្បធម៌ជំនួញរបស់ចិនដែលមានតម្លៃមិនគួរត្រូវមើលស្រាលដោយអ្នកដែលចង់ចូលទៅកាន់ទីផ្សារចិនដែរ។

**បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការធ្វើទីផ្សារផ្លែស្វាយ៖**

⇒ តើក្រុមហ៊ុនមានសម្ភារៈផ្សព្វផ្សាយសមស្របសម្រាប់អតិថិជននៅក្រៅប្រទេសដូចជា គេហទំព័រ និងខិត្តប័ណ្ណផ្សព្វផ្សាយដែរឬទេ?

⇒ តើក្រុមហ៊ុនបានពិចារណាពីការបកប្រែឯកសារផ្សព្វផ្សាយជាភាសាអង់គ្លេស និងភាសាចិនដែលពាក់ព័ន្ធនឹងគោលដៅទីផ្សារចិនដែរឬទេ?

⇒ តើក្រុមហ៊ុនមានឆន្ទៈក្នុងការធ្វើដំណើរបែបពាណិជ្ជកម្មទៅកាន់ទីផ្សារគោលដៅដើម្បីផ្សព្វផ្សាយ និងធ្វើទីផ្សារផ្លែស្វាយ ក៏ដូចជាធ្វើការចរចាពាណិជ្ជកម្មដែរឬទេ?

ការយល់ដឹង និងការគ្រប់គ្រងហានិភ័យប្រកបដោយភាពជោគជ័យទាក់ទងនឹងការនាំចេញបន្លែរបស់អ្នកត្រូវតែជាចំណុចសំខាន់នៃយុទ្ធសាស្ត្រនាំចេញរបស់អ្នក។ ហានិភ័យដែលត្រូវយល់ដឹងនៅពេលនាំចេញរួមមាន៖

- **ហានិភ័យផ្លូវច្បាប់៖** ទិសដៅនៃការនាំចេញស្ថិតនៅក្រោមច្បាប់ដែលខុសពីច្បាប់កម្ពុជា។ ក្រុមហ៊ុនត្រូវតែទទួលខុសត្រូវដោយខ្លួនឯងពីច្បាប់របស់ប្រទេសចិន (ច្បាប់ជាតិ និងតំបន់) សម្រាប់នាំចេញផ្លែស្វាយ។
- **ការសូកប៉ាន់ អំពើពុករលួយ និងហានិភ័យនៃអំពើពុករលួយ៖** ការសូកប៉ាន់ និងអំពើពុករលួយ គឺជាអំពើខុសច្បាប់នៅក្នុងប្រទេសចិន។ ចូលរួមក្នុងសកម្មភាពណាមួយនៃសកម្មភាពទាំងនេះគឺអំពើខុសច្បាប់។
- **ហានិភ័យនៃអនុលោមភាពចត្តាឡីស័ក៖**ស្វែងយល់ពីលក្ខខណ្ឌតម្រូវចត្តាឡីស័កដែលប្រទេសចិនតម្រូវអោយមាន។
- **ហានិភ័យអត្រាប្តូរប្រាក់៖**ហានិភ័យអត្រាប្តូរប្រាក់អាចកើតឡើងដោយសារតែការប្រែប្រួលនៃតម្លៃរូបិយប័ណ្ណ។
- **ហានិភ័យនៃការមិនបង់ប្រាក់៖** ហានិភ័យដ៏ធ្ងន់ធ្ងរមួយសម្រាប់អ្នកនាំចេញទាំងឡាយគឺនៅតែជាមិនទទួលបាននូវការទូទាត់ទំនិញ។

# 6 បញ្ជីពិព័រណ៍ពាណិជ្ជកម្មពាក់ព័ន្ធនៅក្នុងប្រទេសចិន

| កម្មវិធី | ២០២០ | ទីកន្លែង |
|---|---|---|
| ពិព័រណ៍ពាណិជ្ជកម្មបន្លែ និងផ្លែឈើអន្តរជាតិចិន<br>en.chinafvf.com | ផ្តល់ឲ្យពេលក្រោយ | ក្រុងប៉េកាំង |
| ពិព័រណ៍ពាណិជ្ជកម្មនាំចូលអន្តរជាតិចិន (CIIE)<br>www.ciie.org/zbh/en | ផ្តល់ឲ្យពេលក្រោយ | ក្រុងសៀងហៃ |
| ពិព័រណ៍ Asia Fruit Logistica<br>www.asiafruitlogistica.com | ខែកញ្ញា ១៦-១៨ | ប្រទេសសិង្ហបុរី |
| ពិព័រណ៍ ifresh Asia Fruit & Vegetable Industry Expo<br>en.ifreshfair.cn | ខែវិច្ឆិកា ១០-១២ | ក្រុងសៀងហៃ |
| ពិព័រណ៍ Asia Fresh<br>www.asiafreshexpo.com | ខែវិច្ឆិកា ២៧-២៨ | ក្រុងសៀងហៃ |

# 7 ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ ជំហាន/ដំណើរការនៃការដាក់ពាក្យសុំវិញ្ញាបនប័ត្រភូតគាមអនាម័យ



## ឧបសម្ព័ន្ធទី ២៖ ការប្រកាសពន្ធគយ (កម្ពុជា)

### បទបញ្ញត្តិយោង

- ប្រកាសលេខ ១៤៤៧ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីបទប្បញ្ញត្តិ និងនីតិវិធីស្តីពីការប្រកាសពន្ធគយ។
- សេចក្តីណែនាំលេខ ១៣០៨ អ.ន.គ.រ ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០៩ ស្តីពីនីតិវិធី និងការទទួលខុសត្រូវលម្អិតក្នុងការអនុវត្តមុខងារប្រកាសពន្ធគយ (ឯកសាររដ្ឋបាលគយតែមួយគត់-SAD) តាមរយៈវិធីសាស្ត្រអេឡិចត្រូនិក។

### <u>និតិវិធីនៃការប្រកាសពន្ធគយនៅ ASYCUDA</u>

ការដាក់លិខិតប្រកាសពន្ធគយតាមអេឡិចត្រូនិច (ឯកសាររដ្ឋបាលគយតែមួយគត់-SAD) តាមរយៈប្រព័ន្ធដំណើរការពន្ធគយស្វ័យប្រវត្តិថ្មី ហៅថាប្រព័ន្ធស្វ័យប្រវត្តិកម្មលើទិន្នន័យគយ (ASYCUDA) អនុវត្តតាមដំណើរការតាមដ្យាក្រាម ASYCUDA ខាងក្រោម។




នីតិវិធីទូទៅដែលត្រូវអនុវត្តដោយអ្នកនាំចូល អ្នកនាំចេញ និងអ្នកតំណាងរបស់ពួកគេសម្រាប់ការដាក់ការប្រកាសពន្ធគយតាមអេឡិចត្រូនិចត្រូវបានពិពណ៌នាដូចខាងក្រោម:

### ១. ការរៀបចំ និងបោះពុម្ពឯកសារប្រកាសពន្ធគយ

ជើងសារគយ ឬអ្នករៀបចំពន្ធគយបញ្ចូលព័ត៌មានរបស់លិខិតប្រកាស SAD ដោយផ្ទាល់ទៅក្នុងប្រព័ន្ធ ASYCUDA ។ កុំព្យូទ័រ នឹងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការប្រកាសពន្ធគយដោយមានឯកសារយោងនៅក្នុងប្រព័ន្ធ ហើយធ្វើការពិនិត្យមួយចំនួន។ ប្រព័ន្ធនេះនឹងអនុញ្ញាតឱ្យចុះបញ្ជីការប្រកាសពន្ធគយពេលដែលព័ត៌មានត្រូវបានបំពេញ និងមានសុពលភាព។ ការប្រកាសអំពីពន្ធគយដែលបានចុះបញ្ជីអាចត្រូវបានលុបចោលដោយមានការអនុញ្ញាតពី GDCE។ មានតែការប្រកាសពន្ធគយដែលបានចុះបញ្ជីប៉ុណ្ណោះដែលត្រូវបានចាត់ទុកថាជាឯកសារស្របច្បាប់។

បន្ទាប់ពីការចុះបញ្ជី ជើងសារគយ ឬអ្នកប្រកាសពន្ធត្រូវបោះពុម្ព និងចុះហត្ថលេខាលើលិខិតប្រកាសSAD ចំនួន **២ច្បាប់** ដែលភ្ជាប់ជាមួយឯកសារចាំបាច់ទាំងអស់ ហើយប្រគល់ទៅឲ្យមន្ត្រីគយដែលទទួលបន្ទុក។

ប្រព័ន្ធនេះនឹងជូនដំណឹងដោយស្វ័យប្រវត្តិដល់ជើងសារគយ ឬអ្នកប្រកាសពន្ធគយអំពីស្ថានភាពនៃដំណើរការប្រកាសពន្ធគយ។

### ២ .ការដាក់ឯកសារប្រកាសពន្ធគយ

មន្ត្រីគយទទួលបន្ទុកផ្នែកត្រួតពិនិត្យផ្ទាល់នឹងពិនិត្យមើលឯកសារថតចម្លងលិខិតប្រកាស SAD ដែលបានចុះបញ្ជី និងឯកសារភ្ជាប់ជាមួយព័ត៌មាននៅក្នុងប្រព័ន្ធដើម្បីធានាថាលិខិតប្រកាស SAD ត្រូវបានបំពេញយ៉ាងត្រឹមត្រូវ ច្បាស់លាស់ និងអាចអានបាន និងចុះហត្ថលេខាដោយជើងសារគយ ឬអ្នកប្រកាសពន្ធ ហើយឯកសារចាំបាច់ទាំងអស់ត្រូវភ្ជាប់ជាមួយសំណៅដើមលិខិតប្រកាស SAD ដែលបានចុះបញ្ជី។

មន្ត្រីគយអាចមិនទទួលលិខិតប្រកាស SAD ណាមួយដែលមិនបានបំពេញតាមតម្រូវការខាងលើ។

### ៣. ផ្លូវសម្រាប់ដំណើរការវិនិច្ឆ័យលិខិតប្រកាស SAD៖

នៅពេលដែលលិខិតប្រកាស SAD ត្រូវបានត្រួតពិនិត្យត្រឹមត្រូវ និងរួចរាល់ហើយ មន្ត្រីគយនឹងវាយតម្លៃលិខិតប្រកាស SAD ដោយប្រើប្រព័ន្ធដែលរៀបចំជាស្រេច។ ដោយប្រើលក្ខណៈវិនិច្ឆ័យគ្រប់គ្រងហានិភ័យ ប្រព័ន្ធនេះនឹងកំណត់ផ្លូវដំណើរការវិនិច្ឆ័យសម្រាប់ការប្រកាសពន្ធដូចខាងក្រោម៖

**ផ្លូវពណ៌ក្រហម៖** លិខិតប្រកាសSAD ត្រូវតែពិនិត្យពិច័យ (ពិនិត្យឯកសារយ៉ាងលំអិត)។ ទំនិញត្រូវឆ្លងកាត់ការធ្វើអធិការកិច្ចមុនពេលបញ្ជូនលិខិតប្រកាស SAD ទៅផ្លូវពណ៌បៃតង និងវាយតម្លៃដោយគយ។

